# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយឈ្មោះ អ៊ឹ វណ្ណា ភេទប្រុស អាយុ៨៩ឆ្នាំ

## ជនានខ្មែរក្រហម«កុមារកងចល័ត»

## រស់នៅភូមិលេខ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តកំពង់សោម ។

## ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ ឡុង ដានី

ដានីៈ ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូ ពូឈ្មោះអីដែរ?

វណ្ណាៈ ខ្ញុំឈ្មោះ អ៊ឹ វណ្ណា ។

ដានីៈ អ៊ឹ វណ្ណា?

វណ្ណាៈ បាទ ។

ដានីៈ អាយុប៉ុន្មានហើយសព្វថ្ងៃ?

វណ្ណាៈ ខ្ញុំ៤៩ ។

ដានីៈ អាយុ៤៩?

វណ្ណាៈ បាទ ។

ដានីៈ ស្រុកកំណើតកើតជា?

វណ្ណាៈ ខ្ញុំស្រុកកំណើតកើតនៅក្រុងព្រះសីហនុហ្នឹងតែម្តង ។

ដានីៈ នៅភូមិអីឃុំអី?

វណ្ណាៈ កើតនៅហ្នឹងតែម្តង ។

ដានីៈ ភូមិអីគេហ្នឹង?

វណ្ណាៈ អត់មានភូមិទេ ពីមុនគេហៅតែក្រុងព្រះសីហនុតែម្តង ។

ដានីៈ គេហៅក្រុង?

វណ្ណាៈ បាទ!អ្នកជិតខាងនិយាយថា គេចង់សួរលំនៅបច្ចុប្បន្ន«វណ្ណាឆ្លើយតបវិញថា បច្ចុប្បន្នគេមិននិយាយទេ គេនិយាយពីកំណើតយើងកើត ។

ដានីៈ ចឹងពីមុនមកគេអត់ហៅចឹងក្នុងបញ្ជីរជាតិក្នុងសំបុត្រកំណើតនោះអត់មានដាក់ភូមិសង្កាត់អី?

វណ្ណាៈ មានឥឡូវមានដាក់ ដាក់ភូមិ១សង្កាត់លេខ៣ពីមុនអត់ទេ ។

ដានីៈ តែពីមុនមកពូកើតនៅហ្នឹងហើយក្រោយ៧៩ពូត្រឡប់មកនៅហ្នឹងវិញ?

វណ្ណៈ    បាទ!ខ្ញុំត្រឡប់ពីស្រែអំបិលមកវិញមកនៅបាត្រាង នៅភូមិបាត្រាង បានចេញពីបាត្រាងមក បានវិលចូលមកក្រុង ចូលមកក្រុងដោយសារឪពុកខ្ញុំជាបុគ្គលិករដ្ឋករទឹកចឹង ។

ដានី:    បាទ ។

វណ្ណៈ    គេក៏ហៅអ្នកធ្វើការចាស់ៗមកចូលធ្វើការខ្ញុំក៏តាមគាត់មកបាទ ។

ដានី:    បាទ ។

វណ្ណៈ    ចាប់ផ្តើមដំបូងគេថាអត់មានសាលារៀនចឹងនាំគ្នាទៅរៀបចំវត្តដើម្បីនាំសិស្សរៀនសូត្រកាល ហ្នឹងសុទ្ធតែក្មេងៗ សុទ្ធតែតូចៗហ្នឹងណាស់ខ្ញុំអីចូលថ្នាក់ទី១ហ្នឹង ។

ដានី:    បាទ ។

វណ្ណៈ    ហើយក៏រៀបចំចឹងទៅគេថារៀបចំកន្លែងវត្តហ្នឹងគេឲ្យចូលរើឃ្លាំងអីហ្នឹង ខ្ញុំថាបន្ទប់អីល្វិតៗ ចឹងដល់ពេលហ្នឹងឃើញមានខ្មោះមានអីណាស់ ខ្ញុំថានេះសុទ្ធតែខ្មោះដាក់មនុស្សគេ ហើយ មានកន្លែងឥដ្ឋការ៉ូខ្លះមានឈាមដានជាប់នៅហ្នឹង ។

ដានី:    អូ! ។

វណ្ណៈ    ចឹងក៏រើខ្មោះចេញមកក្រៅចឹងទៅ រៀបចំសាលារៀននៅខាងក្នុងហ្នឹងទៅ ។

ដានី:    ចឹងពេលអើ!ខ្ញុំចង់សួរបកទៅវិញទៀតពូ ចឹងស្រុកកំណើតពូគេហៅក្រុងព្រះសីហនុតែម្តង?

វណ្ណៈ    បាទ!ក្រុងព្រះសីហនុ ។

ដានី:    ចឹងកាលហ្នឹងគេអត់មានដាក់សង្កាត់ដូចឥឡូវទេ?

វណ្ណៈ    អត់ទេ កាលពីតាខ្ញុំធ្វើការមុនដំបូងគាត់នៅរដ្ឋករទឹកហ្នឹង តែគាត់នៅម៉ាស៊ីនទឹកលើនេះ ។

ដានី:    បាទ!ម៉ាស៊ីនទឹកលើ?

វណ្ណៈ    បាទ! ពីកំណើតកើតនៅហ្នឹង ដល់ហើយបានផ្ទេរគាត់ពីលើហ្នឹងមកនៅយាមម៉ាស៊ីនបូមទឹកនៅ ខាងក្រោមនេះវិញ ។

ដានី:    បាទ! ចុះកាលពីក្មេងៗពូរៀនសូត្រនៅណាដែរ?

វណ្ណៈ    ខ្ញុំរៀនសូត្រនៅសាលាចាស់នេះ កាលហ្នឹងខ្ញុំចូលរៀនថ្នាក់ទី១២កាលហ្នឹង ។

ដានី:    សាលាចាស់ណា?

វណ្ណៈ    សាលាចាស់ហ្នឹងនៅផ្ទុំគេហៅថាឧត្តមនិយមហ្នឹងណាស់ ពីមុន ។

ដានី:    កន្លែងឧត្តមនិយម?

វណ្ណៈ    បាទ!ផ្លូវទៅដែហ្នឹងណា៎ នៅកន្លែងហ្នឹងជាប់កន្លែងសារាចរណ៍ហ្នឹង ហ្នឹងតាមខ្ញុំចាំច្បាស់ ។

ដានី:    បាទ!ចឹងឪពុកពូគាត់ឈ្មោះអីដែរ?

វណ្ណៈ ឪពុកខ្ញុំឈ្មោះអ៊ឹ ស៊ុន ។

ដានីៈ ឈ្មោះ អ៊ឹ ស៊ុន?

វណ្ណៈ បាទ ។

ដានីៈ ឥឡូវគាត់ស្លាប់ឬមួយនៅរស់?

វណ្ណៈ ប៉ាស្លាប់ហើយ ។

ដានីៈ កាលពីមុនគាត់ធ្វើអី?

វណ្ណៈ ពីមុនគាត់ជាបុគ្គលិករដ្ឋករទឹក ។

ដានីៈ បុគ្គលិករដ្ឋករទឹកនេះហ្នឹង?

វណ្ណៈ បាទ ។

ដានីៈ ចឹងរដ្ឋករទឹកហ្នឹងពីដើមក៏នៅហ្នឹងដែរ?

វណ្ណៈ ពីដើមនៅហ្នឹងដែលបាទ ។

ដានីៈ នៅជិតវត្តហ្នឹងដែរ?

វណ្ណៈ បាទ!ជិតវត្តដែលក្រោមវត្តហ្នឹង ។

ដានីៈ បាទ!ៗចឹងម្តាយពូ?

វណ្ណៈ ម្តាយក៏ស្លាប់ដែរ ។

ដានីៈ ចឹងម្តាយពូគាត់ឈ្មោះអីដែរ?

វណ្ណៈ គាត់ឈ្មោះ អាន ឡូង ។

ដានីៈ អាន ឡូង?

វណ្ណៈ បាទ!អាន ឡូន ។

ដានីៈ គាត់ស្លាប់ពេញកាលដែរ?

វណ្ណៈ គាត់ស្លាប់តាំងពី៨០ប៉ុន្មានទេ ។

ដានីៈ ចឹងឪពុកពូ?

វណ្ណៈ ឪពុកខ្ញុំទើបស្លាប់ឆ្នាំ២០០២អីប៉ា ។

ដានីៈ ចឹង២០០២?

វណ្ណៈ បាទ ។

ដានីៈ ចឹងពូមានបងប្អូនបង្កើតប៉ុន្មាននាក់?

វណ្ណៈ ខ្ញុំទាំងអស់មាន៩នាក់ ។

ដានី៖ ចឹងបងប្អូន៥នាក់ចឹងពូជាកូនទីប៉ុន្មាន?

វណ្ណៈ ខ្ញុំកូនទី១ ។

ដានី៖ ចឹងបងគេបង្អស់?

វណ្ណៈ បាទ! បើរាប់ទាំងអស់១០ នោះតែស្លាប់ក្នុងសម័យប៉ុល ពត ។

ដានី៖ អូ! ចឹង?

វណ្ណៈ បាទ ។

ដានី៖ គ្រួសារពូគាត់ឈ្មោះអីដែរ?

វណ្ណៈ ប្រពន្ធខ្ញុំនេះឈ្មោះ គេដាក់ក្នុងនេះជា គារ៉ា ប៉ុន្តែនៅក្នុងអត្តសញ្ញាណបត្រគេហៅជា តារា ។

ដានី៖ ជា តារា?

វណ្ណៈ បាទ! ប្រពន្ធនិយាយថា គេសរសេរជា តារាវិញ វណ្ណនិយាយវិញ ចុះគេវៃចឹងហើយយើងខ្ជិលកែយើងដាក់ចឹងទៅ"អ្នកជិតខាងនិយាយថា តែកែលិចតែកើតលុយទៀត" ។

ដានី៖ ចឹងប្រពន្ធពូជាអ្នកស្រុកកំណើតនៅហ្នឹងដែរ?

វណ្ណៈ ប្រពន្ធខ្ញុំអ្នកស្រុកកំណើតកំពង់ធំ ។

ដានី៖ អ្នកកំពង់ធំ?

វណ្ណៈ បាទ ។

ដានី៖ ចឹងសព្វថ្ងៃពូរស់នៅក្នុងភូមិឃុំអីដែរ?

វណ្ណៈ នៅភូមិ១ ។

ដានី៖ ភូមិទី១?

វណ្ណៈ បាទ! សង្កាត់លេខ៣ ។

ដានី៖ សង្កាត់លេខ៣?

វណ្ណៈ បាទ! ក្រុម៩ ខេត្តព្រះសីហនុហ្នឹង ។

ដានី៖ ចឹងក្រុម៩?

វណ្ណៈ បាទ ។

ដានី៖ ខេត្តព្រះសីហនុ?

វណ្ណៈ បាទ ។

ដានី៖ ស្រុកអីគេហៅស្រុកប្ញខណ្ឌឥឡូវ ។

វណ្ណៈ ឥឡូវគេហៅក្រុង ។

ដានី៖ ក្រុងព្រះសីហនុ?

វណ្ណៈ បាទ ។

ដានី៖ ពូមានកូនចៅទាំងអស់ប៉ុន្មាននាក់ដែរ?

វណ្ណៈ ខ្ញុំទាំងអស់៤នាក់ ។

ដានី៖ ចឹង៤នាក់?

វណ្ណៈ ៥នាក់តែមួយនៅស្រុក ។

ដានី៖ បាទ!ចឹងពូសព្វថ្ងៃប្រកបមុខរបររកស៊ីអី?

វណ្ណៈ ខ្ញុំរត់ម៉ូតូឌុបហ្នឹង ។

ដានី៖ រត់ម៉ូតូឌុបចឹងអត់មានធ្វើអីទៀតទេ?

វណ្ណៈ អត់ទេ ពីមុនគេចេះតែហៅការងារក្រសួងតែតែអត់ធ្វើចេះតែគេចៗរហូត ។

ដានី៖ បាទ!ចឹងកាលហ្នឹងពូរៀនដល់ថ្នាក់ណា ពូថារៀនសាលាចាស់?

វណ្ណៈ សាលាចាស់ពីសង្គមហ្នឹងខ្ញុំបានត្រឹមថ្នាក់ទី១២ ថ្នាក់ទី១២បានប្រហែលជាពីរឆ្នាំទៅបានបែកប៉ុល ពត ។

ដានី៖ បែកប៉ុល ពតបែកឆ្នាំ៧៥?

វណ្ណៈ បាទ!៧៥ទៅ ។

ដានី៖ បាទ!កាលហ្នឹងពូអាយុប៉ុន្មាន?

វណ្ណៈ ខ្ញុំអត់នៅចាំដែលកាលហ្នឹង ដឹងថានៅតូចដែរ ស្មាទោសយើងមិនសមនិយាយទេ ដើរទៅរៀនលេចអាចម៍ដាក់ខោនៅឡើយហ្នឹង នៅចាំអនុស្សាវរីយ៍ ។

ដានី៖ បាទ!ចឹងដល់ប៉ុល ពតឆ្នាំ៧៥ហ្នឹងយ៉ាងម៉េចទៀតទៅ?

វណ្ណៈ គេជម្លៀសប្រជាជនឲ្យចេញពីក្រុងទៅនៅថាឲ្យទៅស្រុកទៅភូមិណាស់ តែទៅដល់ពាក់កណ្ដាលផ្លូវត្រឹមវាលវិញហ្នឹង ពួកប៉ុល ពតគេកាត់ថា ប្រជាជនថ្មីចឹងគេឲ្យទៅខាងខេត្តកោះកុង គេកាត់ទៅខាងកោះកុងគេហៅយើងដាក់ឡានទៅកោះកុងចឹងទៅ ដល់កោះកុងគេឲ្យយើងស្នាក់នៅគេហៅថាវត្តនេះវត្តបឹងព្រៀវ ។

ដានី៖ បាទ ។

វណ្ណៈ នៅវត្តហ្នឹងបានមួយយប់ក៏គេឲ្យធ្វើដំណើរទៅភូមិអង់កែវអាហ្នឹងឆ្លងព្រែកទៅទៀតហើយហ្នឹងព្រៃក្អំតែម្ដងនៅហ្នឹងរហូតទៅ នៅរហូតប្រហែលជាប៉ុនអានេះប្រហែលជា១២ទៅ១៣ឆ្នាំហ្នឹងគេចាប់ផ្ដើមរើសកងចល័តហើយឲ្យធ្វើកងចល័ត ។

ដានី៖ បាទ ។

វណ្ណៈ៖ ដើរកាប់ដីជួយរែកទំនប់អីចាស់ៗហ្នឹង ទៅបែកពីម៉ែឪរហូត ។

ដានី៖ "អ្នកជិតខាងនិយាយថា បែកឆ្នាំណាដែលគេសម្លាប់?

វណ្ណៈ៖ យើងអត់ចាំទេរឿងឆ្នាំ ។

ដានី៖ បាទ ។

វណ្ណៈ៖ បែករហូតចឹងដល់ពេលតាំងពីហ្នឹងមកក៏បែក៧៩ហ្នឹង បានជួបប៉ាខ្ញុំវិញហើយគេថាវៀតណាមវ៉ៃជិតដល់ហើយ ។

ដានី៖ បាទ ។

វណ្ណៈ៖ ជិតដល់ក៏គេជ្រើសរត់ទៅរកឪពុកម្ដាយអស់ហើយខ្ញុំមិនដឹងថាឪពុកម្ដាយនៅណាទេ តែខ្ញុំមានស្គាល់តាម្នាក់គាត់ថា ប៉ាឯងអញឃើញមិញ អញឃើញនៅខាងបឹងព្រៀវនោះឯងទៅមើលហើយនៅដល់ជួបគាត់ហ្នឹង គាត់នាំទៅ គាត់ហ្នឹងគាត់ថាគាត់មកយកស្រូវអីហ្នឹង ។

ដានី៖ អ៊ី! ។

វណ្ណៈ៖ យកស្រូវដើម្បីធ្វើស្បៀងព្រោះមេប៉ុល ពតគេឲ្យមកយកណាស់ គេហៅទៅនោះគាត់គេហៅថាខាងសហករណ៍ណាស់ ។

ដានី៖ បាទ ។

វណ្ណៈ៖ ខាងដឹកជញ្ជូនស្រូវដើម្បីប្រមូលផលស្រូវបានហ្នឹងយកទៅលាក់ទុកនៅភ្នំដើម្បីផ្គត់ផ្គង់ទ័ពប្រជាជនអីចឹង ។

ដានី៖ បាទ ។

វណ្ណៈ៖ ក្រោមមកទៀតបានវៀតណាមគាត់រំដោះបានចឹងនាំគ្នាត្រឡប់មកវិញ ត្រឡប់មកវិញប៉ាខ្ញុំថាធ្វើស្រែម្ដងហើយ ធ្វើស្រែនៅអូរចំណារនេះ ។

ដានី៖ បាទ ។

វណ្ណៈ៖ នៅអូរចំណារនៅរបបគេឲ្យស៊ីលំបាកពេកចឹង នឹកឃើញថាឈប់នៅអូរចំណារហើយមកនៅស្នាច់ដែង ។

ដានី៖ បាទ ។

វណ្ណៈ៖ មកនៅស្នាច់ដែងបានប្រហែលមួយខែពីរ គេថាស្នាច់ដែងវាលំបាកដែលចឹងមានអីមួយឈ្មោះតាផុនៗចឹងឯងមកនៅកន្ទែងអញមកនៅបិតត្រាង បិតត្រាង រៀមយើងនេះ ។

ដានី៖ បាទ ។

វណ្ណៈ    ក៏នាំគ្នាមកដល់ហ្នឹង  ក៏គេចាប់ផ្ដើមប្រកាសរកបុគ្គលិកចាស់ៗឲ្យចូលធ្វើការហ្នឹង ។

ដានី:    បាទ ។

វណ្ណៈ    ក្រុងព្រះសីហនុហ្នឹងមុនដំបូងបំផុតគេឲ្យតែកំពង់ផែនិងរដ្ឋករទឹកទេ   ចូលមករៀបចំបណ្ដាញទឹកក្នុងក្រុង ។

ដានី:    បាទ ។

វណ្ណៈ    ហើយបានប៉ាចូលមកប្រហែលជាមួយខែឯងមកតាមអញមក   មកហ្នឹងលក្ខណៈបាយរួមទេ ហើយពេលហ្នឹងមានឡានអាស្រ៊ីបរបស់អាមេរិកាំងមួយហ្នឹង  ពេលបាយហ្នឹងគេដឹកបុគ្គលិកទៅខ្ញុំអីទៅហូបបាននៅឃ្លាំងប្រាក់នេះ ។

ដានី:    បាទ ។

វណ្ណៈ    ហូបបាយចឹងក៏គេបញ្ជាំងកុនអីដល់ម៉ោង៩យប់បានគេដឹកមកអន្តេវាសិកដ្ឋានយើងវិញ  ព្រលឹមឡើងមានឡាននិងមួយសម្រាប់ដឹកមនុស្សហើយនិងអាត្រាក់មួយសម្រាប់ដឹកកម្មករទៅធ្វើការ ហើយកាលហ្នឹងប៉ាខ្ញុំគាត់ប្រធានក្រុម ។

ដានី:    ប្រធានក្រុម?

វណ្ណៈ    បាទ!ប្រធានក្រុមខាងបណ្ដាញតទឹកតអីហ្នឹង ។

ដានី:    ចឹងពូគាត់ចូលមកនៅកន្លែងភូមិទី១ហ្នឹង  សង្កាត់លេខ៣ហ្នឹងតាំងពីឆ្នាំមកចឹង?

វណ្ណៈ    និយាយរួមតាំងពី៧៩មកតែម្ដង ។

ដានី:    ៧៩ខែប៉ុន្មានបើតាមពូចាំ?

វណ្ណៈ    ខែ១ ។

ដានី:    ខែ១ចឹង៧មកវាខែ១បែក?

វណ្ណៈ    បាទ!បែកហើយក្រោយពីហ្នឹងប្រហែលជាប៉ុន្មានទេ   មិនដល់មួយខែទេ   អត់ដល់មួយខែទេ ព្រោះគេត្រូវការប្រកាសទូទាំងប្រទេសថា  បុគ្គលិកចាស់កំពង់ផែព្រោះគេអភិវឌ្ឍន៍កំពង់ផែមុនដើម្បីដំណើរការកាលហ្នឹងមានរទេះភ្លើងដឹកពោតដឹកអីណា  មានស្រូវសាលីដើម្បីយកចែកកម្មករទូទាំងប្រទេសហ្នឹង ។

ដានី:    បាទ ។

វណ្ណៈ    ដល់ហើយគេត្រូវចូលកំពង់ផែ  រដ្ឋករទឹកអីហើយប៉ាខ្ញុំគាត់ចូលតាំងពីហ្នឹងមកតែម្ដង ។

ដានី:    បាទ ។

វណ្ណៈ    ប្រកាសហើយគាត់ទាញមិត្តភក្តិគាត់ដែលស្គាល់ៗមានប៉ុន្មានប្រមូលមកធ្វើការទាំងអស់គ្នា ។

ដានី៖ បាទ ៗ

វណ្ណា៖ ខ្ញុំមកតាមគាត់ដោយចឹងទៅ ចឹងហើយបានជាខ្ញុំដឹងរឿងច្រើនណាស់ ៗ

ដានី៖ ចឹងគ្រួសារពូមកទាំងអស់គ្នា?

វណ្ណា៖ បាទ ៗ

ដានី៖ ៧៩ហ្នឹង ចឹងគ្រួសារផ្សេងៗទៀតមកប៉ុន្មានគ្រួសារទៅ?

វណ្ណា៖ ទាំងអស់កាលហ្នឹងវាច្រើនដែរ តែត្រង់ថាកាលហ្នឹងវានៅបែកគ្នាខ្លះនៅខាងម្តុំ«ស៊ីតេ»អ្នកខ្លះនៅភូមិគេហៅថាភូមិចំការចំរុះកន្លែងធ្វើសាវាចរណ៍យើងហ្នឹង ៗ

ដានី៖ បាទ ៗ

វណ្ណា៖ ហើយនៅហ្នឹងតែប៉ុន្មានគ្រួសារទេ ៗ

ដានី៖ មានប៉ុន្មានពូចាំទេ?

វណ្ណា៖ ប្រហែលជា៥ទៅ៦គ្រួសារប៉ុណ្ណឹងឯង ៗ

ដានី៖ ចឹងមាន៥ - ៦គ្រួសារ?

វណ្ណា៖ បាទ ៗ

ដានី៖ គ្រួសារណាខ្លះ?

វណ្ណា៖ ឥឡូវបែកគ្នាអស់ហើយសុទ្ធតែស្លាប់ ច្រើនស្លាប់ហ្នឹង តាដែលខ្ញុំថាហ្នឹងសុទ្ធស្លាប់ ៗ

ដានី៖ ចុះកាលពីជំនាន់ប៉ុល ពតហ្នឹងពូមានបងប្អូនស្លាប់ប៉ុន្មាននាក់ដែរ?

វណ្ណា៖ ខ្ញុំដូចខ្ញុំថា អាសម្លាប់ដុតទាំងរស់ហ្នឹងម្នាក់ហើយកើតមកហ្នឹងពីរនាក់ដែរ ៗ

ដានី៖ ចឹងពូអាចរៀបរាប់បានទេ ថាប្អូនពូត្រូវគេដុតទាំងរស់ហ្នឹងមូលហេតុអីដែរ ដំបូងយ៉ាងម៉េចបានដល់ថ្នាក់គេដុតទាំងរស់ហ្នឹង?

វណ្ណា៖ ដុតទាំងរស់ហ្នឹងដូចខ្ញុំថាភាគច្រើនវាសេរីដូចខ្ញុំថាហ្នឹង ពាក្យថាសេរីបានន័យថាយើងមិនគោរពអង្គការចាត់តាំងរបស់គេ ៗ

ដានី៖ បាទ ៗ

វណ្ណា៖ ហើយគេចាប់យើងមកដាក់គុកដើម្បីលុតដំរៀនសូត្រយើងមិនព្រមរៀនសូត្រយើងគិតតែពីគាស់ខ្មោះរត់ណាស់ រត់ហ្នឹងក៏មិនចូលធ្វើការទេ រត់បេះដើរស៊ីស្លឹកឈើស្លឹកព្រៃរុះហ្នឹងណាស់ ៗ

ដានី៖ បាទ ៗ

វណ្ណៈ ហើយដកជីឡូងអីគេស៊ីគេចាប់បានគេយកមកដាក់គុកទៀតគេវ៉ៃឡើងបែកក្បាលហូរឈាមអស់ហើយ ។

ដានី: បាទ ។

វណ្ណៈ វ៉ៃនៅមុខហ្នឹង ហើយគេដុតហ្នឹងគេដុតនៅហ្នឹងមុខដែរ ពេលហ្នឹងខ្ញុំនៅវែកទំនប់ចឹង ទំនប់ចឹងព្រៀវហ្នឹង ចឹងបានខ្ញុំថាថ្ងៃណាខ្ញុំមានឱកាសមានលុយកាក់ច្រើនខ្ញុំទៅមើលកន្លែងគេកប់ប្អូនខ្ញុំហ្នឹងណាស់ ។

ដានី: បាទ ។

វណ្ណៈ គេចាប់ដុតទាំងរស់តែម្តងគេចងគ្នាវាពីរនាក់ អាមួយឈ្មោះ អា តា ៗ ។

ដានី: បាទ ។

វណ្ណៈ គេចាប់វាចងជាប់និងដើមដូងណាស់ ។

ដានី: បាទ ។

វណ្ណៈ ហើយបន្តភ្លើងដុតតែម្តងស្រែករោរ៍ដូចគោចឹង ។

ដានី: ចឹងពូឃើញផ្ទាល់ភ្នែក?

វណ្ណៈ ឃើញផ្ទាល់ភ្នែកតែម្តងបានថាចឹងវាឲ្យអ្នកអ្នកធ្វើការមើលទាំងអស់កុំឲ្យយើងយកគំរូតាមចឹងថាជនសេរីអីចឹង ដល់វាស្លាប់ដាច់ខ្យល់ចឹងបានគេយកវាកប់ដើងទំនប់ហ្នឹង ។

ដានី: ប្អូនពូឈ្មោះអីដែលគេសម្លាប់ហ្នឹង?

វណ្ណៈ ឈ្មោះ អា ទិ ។

ដានី: ឈ្មោះ អាទិ?

វណ្ណៈ បាទ ។

ដានី: បន្ទាប់ទីប៉ុន្មាន?

វណ្ណៈ អាហ្នឹងទីពី២បន្ទាប់ខ្ញុំ ។

ដានី: កាលគេដុតហ្នឹងអាយុគាត់ប្រហែលជាប៉ុន្មាន?

វណ្ណៈ កាលហ្នឹងខ្ញុំអត់នៅចាំ ។

ដានី: ប្អូនពូប៉ុន្មានឆ្នាំ?

វណ្ណៈ ប្អូនខ្ញុំមួយឆ្នាំ ។

ដានី: ចឹងប្អូនតែមួយឆ្នាំទេ?

វណ្ណៈ បាទ ។

ដានី៖ ចឹងដំបូងមុនគេចាប់គាត់ គាត់ធ្វើអី?

វណ្ណៈ មុនចាប់ប្អូនខ្ញុំ ។

ដានី៖ បាទ!ប្អូនពូ?

វណ្ណៈ វាអត់មានធ្វើស្អីទេ វាជាកុមារកាប់ជីកន្រ្ទាងខែត្រអីហ្នឹងធម្មតាហ្នឹង ។

ដានី៖ ចឹងកាប់ជីកន្រ្ទាងខែត្រធម្មតាទេ?

វណ្ណៈ បាទ!ចុះនៅតូចៗដែលនៅទ្រឹសៗជាងកូនខ្ញុំបន្តិច ។

ដានី៖ នៅក្នុងកងជាមួយពូដែលប្តូរផ្សេងគ្នា?

វណ្ណៈ នៅកងជាមួយគ្នាបានខ្ញុំដឹងប្រវត្តិច្បាស់ហ្នឹង ។

ដានី៖ ចឹងគាត់កាត់កន្រ្ទាងខែតទៅមូលហេតុដំបូងគេចាប់គាត់ដាក់គុក?

វណ្ណៈ បាទៗ!ដាក់គុកវាចេះតែគាស់គុករត់ ។

ដានី៖ ចឹងមូលហេតុដែលគេចាប់គាត់ដាក់គុកដោយសារតែមូលហេតុអីគេ?

វណ្ណៈ ដោយសារគេចោទវាថា វាហ្នឹងគេចវេសការងារ ។

ដានី៖ គេចវេសការងារ?

វណ្ណៈ គេចវេសការងារអត់មានធ្វើការងារបំរើជាតិអីចឹង វាចេះតែគេចចេះតែសម្ងំសម័យប៉ុល ពតដឹងស្រាប់ដល់ពេលនេះគេចាប់យើងហើយ ។

ដានី៖ ពីណាអ្នកចាប់ដំបូង?

វណ្ណៈ ចាប់ហ្នឹងគេហៅថាកុមារឈ្លប កងឈ្លបយើងហ្នឹងក្មេងទេ យើងស្មានអាយុទៅប្រហែលជា ១០ឆ្នាំ ស្ពាយអ៊ីមម៉ាសីមួយដើមកាន់កាំភ្លើងអូសដីហើយអាហ្នឹង ។

ដានី៖ ហ្នឹងគេចាប់នៅភូមិណាទៅ?

វណ្ណៈ កាលចាប់ហ្នឹងនៅភូមិបឹងព្រៀវ ។

ដានី៖ ភូមិបឹងព្រៀវ?

វណ្ណៈ បាទ ។

ដានី៖ ឃុំអីនៅហ្នឹង?

វណ្ណៈ ខ្ញុំដឹងថាភូមិបឹងព្រៀវ ឃុំបឹងព្រៀវដែលហ្នឹងដំណើរ ។

ដានី៖ ស្រុក?

វណ្ណៈ ស្រុកស្រែអំបិល ។

ដានី៖ ស្រុកស្រែអំបិល?

វណ្ណៈ ស្រុកស្រែអំបិល ខេត្តកោះកុងកាលហ្នឹង ។

ដានីៈ កាលហ្នឹងគ្រួសារពូគេជម្លៀសទៅនៅហ្នឹងទាំងអស់?

វណ្ណៈ គេជម្លៀសទៅនៅហ្នឹងទាំងអស់បាទ ។

ដានីៈ ចឹងកាលកងឈ្លបកុមារឈ្លបហ្នឹងចាប់គាត់ទៅដាក់កន្លែងណាទៅ?

វណ្ណៈ ចាប់យកទៅដាក់កន្លែងគុកស្រែវាល ។

ដានីៈ គុកស្រែវាល?

វណ្ណៈ បាទ!គុកស្រែវាលហ្នឹង វាលហ្នឹងកណ្ដាលវាលមែនហ្នឹងមានដើមដូងតែម្ដុំហ្នឹង ។

ដានីៈ ដល់ពេលចាប់គាត់ដាក់នៅហ្នឹងទៅគាត់លួចគាស់រត់?

វណ្ណៈ ប្រហែលជាមួយអាទិត្យប្លុកនេះខែទេ រត់រួចសឹងថាមួយអាទិត្យរួចពីរដងក៏មានដែរ គេដាក់វាឡើងចាញ់ចេះហើយរឿងដាក់គុកហ្នឹង ។

ដានីៈ គាត់ពូកែគាស់ឬយ៉ាងម៉េច?

វណ្ណៈ ពូកែគាស់ អត់ដឹងវាមានបច្ចេកទេសអីដឹងយ៉ាងម៉េចវា ខ្ញុំឆ្ងល់ដាក់ច្រវ៉ាក់ទៀតនៅតែគាស់ច្រវ៉ាក់បានទៀតខ្ញុំឆ្ងល់ ។

ដានីៈ គាស់រួចប៉ុន្មានដងទៅ?

វណ្ណៈ រួចតាមខ្ញុំដឹងប្រហែលជាបីដងបានគេនេះចោលហ្នឹង ប៉ុន្តែយកទៅម្ដងៗគេសុទ្ធតែឆក់ខ្សែភ្លើងគេវ៉ៃបើសិនជា ជាវិញអារម្មណ៍យើងក៏អត់មូលដែរ ។

ដានីៈ បាទ! ពេលគេចាប់ម្ដងៗគេវ៉ៃ ចឹងប្រហែលជាចាប់បីដងក្រោយមកគេសម្រេចដុតគាត់ទាំងរស់បណ្ដោយ?

វណ្ណៈ បាទ!ដល់ពេលចឹងគេយកវាមកធ្វើការចឹងទៅគេនឹកឃើញយ៉ាងម៉េចទេ អាកុមារកងឈ្លបគេហ្នឹង មានមេគេថាឯងកុំឲ្យពិបាកពេកឯងបង្ហើយវាឲ្យហើយទៅអា! ហើយគេប្រកាសថា ចឹងបងប្អូនប្រជាជនទាំងអស់មើលគំរូ កុំឲ្យយកគំរូតាមអាមនុស្សខ្មាំងគេហៅខ្មាំង ។

ដានីៈ បាទ ។

វណ្ណៈ ចាប់ចងគ្នាទាំងរស់ចឹងផ្អែកចងជាប់និងដើមដូងគគភ្លើងដុតទៅ ។

ដានីៈ អឺ ។

វណ្ណៈ ដុតឡើងឆេះសក់ក្បាលអីអស់រហូតដល់ស្បែកត្រចៀកអីឆេះខ្ទិចដៃឡើងរួញអស់បានដាច់ខ្យល់ ។

ដានីៈ អឺ ។

វណ្ណៈ ត្រូវនិយាយរួមចង់ខ្សែភ្លើងមិនមែនចង់នេះទេ ចងដៃទៅក្រោយជើងចងដៃចងជើងផ្អែកនិងដើមដូងដុត ។

ដានី: ឆ្នាំណាពូមាននៅចាំឆ្នាំទេ?

វណ្ណៈ ប្រហែលជា៧៧ ។

ដានី: ៧៧?

វណ្ណៈ បាទ ។

ដានី: ខែមានចាំខែទេ?

វណ្ណៈ ខែខ្ញុំអត់ចាំទេ ។

ដានី: ខែហ្នឹងដូចជាខែប្រាំងនិងខែវស្សា?

វណ្ណៈ ខែហ្នឹងខែវស្សា ។

ដានី: ខែវស្សា?

វណ្ណៈ បាទ! យើងបើតាមស្មានមើលប្រហែលជាខែ៦ ។

ដានី: ខែ៦ចឹងកាលហ្នឹងប្រធានដែលឲ្យដុតហ្នឹងគាត់មានតួនាទីអី?

វណ្ណៈ តួនាទីកងទ័ពតែម្តង មេកងទ័ពតែម្តងធ្វើធំតែម្តង មេធំនិយាយក្តោបក្តាប់ប៉ុន្មានភូមិលើប៉ុហ្នឹងជាអ្នកក្តោបក្តាប់ទាំងអស់ ។

ដានី: ឈ្មោះអីដែលប៉ុហ្នឹង?

វណ្ណៈ ខ្ញុំអត់ស្គាល់ឈ្មោះ ។

ដានី: ចឹងអត់ស្គាល់ឈ្មោះទេ?

វណ្ណៈ បាទ ។

ដានី: ចឹងកាលដុតហ្នឹងឪពុកម្តាយពូនិងបងប្អូនផ្សេងៗទៀតមានបានឃើញទេ?

វណ្ណៈ អត់មានបានឃើញទេ ប៉ាខ្ញុំនៅប្រហែលជា១០គីឡូពីកន្លែងហ្នឹងហើយម្តាយខ្ញុំនៅប្រហែលជា២០គីឡូនិយាយរួមប្តីប្រពន្ធក៏អត់បាននៅជាមួយគ្នា ម្តាយខ្ញុំគេឲ្យទៅធ្វើទំនប់សាខនជិតកោះកុងនោះ ។

ដានី: បាទ ។

វណ្ណៈ ហើយប៉ាខ្ញុំនៅអង់កែវ ហើយខ្ញុំនៅខាងបឹងព្រៀវជាមួយវា ។

ដានី: អរ! ចឹងពូគេចាត់ទុកពូជាប្រជាជនថ្មីឬមួយប្រជាជនចាស់?

វណ្ណៈ គេពួកខ្ញុំ១៧មេសា ។

ដានី៖ ចឹងគេហៅពួក១៧?

វណ្ណៈ បាទ!ពួកយើងទើបនិងទៅគេហៅ១៧មេសា ។

ដានី៖ ចឹងប្អូនៗពូដែលកើតក្រោយៗស្លាប់ប៉ុន្មាននាក់ទៀត?

វណ្ណៈ កើតបានតែមួយខែពីរខែអីស្លាប់ពីរនាក់ទៀត ។

ដានី៖ ហ្នឹងស្លាប់ដោយសារអី?

វណ្ណៈ ស្លាប់ដោយសារយើងវាខ្វះជីវជាតិថ្នាំសង្កូវអី ។

ដានី៖ ចឹងក្រៅពីប្អូនពូឪពុកម្ដាយប្អូនប្អូនផ្សេងៗមានគេចាប់ទៅធ្វើទារុណកម្មទៀត?

វណ្ណៈ អត់ទេ ។

ដានី៖ ចឹងមានតែមួយហ្នឹងទេ?

វណ្ណៈ បាទ ។

ដានី៖ ចឹងមានតែពូមួយទេ ដែលបានឃើញផ្ទាល់ភ្នែក?

វណ្ណៈ ខ្ញុំបានឃើញផ្ទាល់ភ្នែក ។

ដានី៖ ចឹងឃើញចឹងពូមានអារម្មណ៍យ៉ាងម៉េច?

វណ្ណៈ អារម្មណ៍ចេះតែតត់ស្លុតហើយធម្មតាប្អូនបង្កើត ដល់ពេលគេធ្វើបាបចឹងយើងមានកំហឹងឈឺចាប់ចឹង ធ្វើម៉េចយើងសុខចិត្តសម្រក់ទឹកភ្នែកដើរគេច ។

ដានី៖ អឺ!បាទចឹងដល់ពេលមកដល់ដំបូងពេលដែលមកនៅហ្នឹងឆ្នាំ៧៩មកដល់ដំបូងពូមានឃើញស្ថានភាពវត្តនិងយ៉ាងម៉េចដែរ វត្តហ្នឹងគេហៅវត្តអីដែរ?

វណ្ណៈ វត្តឥន្ទញ្ញាណ ។

ដានី៖ វត្តឥន្ទញ្ញាណតែប្រជាជនហៅវត្តអី?

វណ្ណៈ ហៅវត្តឥន្ទញ្ញាណហ្នឹងតែម្ដង ។

ដានី៖ ចឹងវត្តឥន្ទញ្ញាណអត់មានឈ្មោះវត្តអី វត្តក្រោមវត្តលើយ៉ាងម៉េច?

វណ្ណៈ មានអ្នកខ្លះចេះតែហៅតែថាវត្តក្រោមអីចឹងទៅណាស់ ។

ដានី៖ តែអ្នកស្រុកភូមិដូចពូហៅវត្តហ្នឹងហៅវត្តអី?

វណ្ណៈ ហៅវត្តឥន្ទញ្ញាណព្រោះយើងហៅឈ្មោះវត្តដែលគេដាក់ណាស់ ។

ដានី៖ ចឹងឈ្មោះវត្តឥន្ទញ្ញាណ?

វណ្ណៈ បាទ ។

ដានី៖ ចឹងពេល៧៩ហ្នឹងពូមកដល់ខែ១ឬខែ២?

វណ្ណៈ ខែ១ហ្នឹង ។

ដានី៖ ចឹងពូមកដល់ដំបូងពូឃើញស្ថានភាពយ៉ាងម៉េចដែរពូ?

វណ្ណៈ វត្តហ្នឹងនិយាយរួមវាទ្រុតទ្រោមអស់ហើយ វិហារថ្មីរាល់ថ្ងៃក៏ខូចអស់ដែលវិហារឈើហ្នឹង វិហារឈើសរសរមូល ។

ដានី៖ បាទ ។

វណ្ណៈ វាធុះធ្លាយវាបាក់បែកអស់ហើយ យើងចេះបោសសម្អាតអីរៀបចំកន្លែងនេះទៅ មុខវត្តហ្នឹងមានគេជីករណ្តៅមួយទៀត កន្លែងដើមចំបក់ ។

ដានី៖ មុខវត្តហ្នឹង?

វណ្ណៈ បាទ!កន្លែងនេះហ្នឹងនិយាយរួមកន្លែងស្វាដក់មិញហ្នឹងណាស់ ។

ដានី៖ បាទ ។

វណ្ណៈ នៅជិតហ្នឹង តែអាគ្រាក់គេលុបហើយជំរៅប្រហែលមុខផ្ទះហ្នឹង ។

ដានី៖ រណ្តៅហ្នឹងជារណ្តៅស្អីគេ?

វណ្ណៈ រណ្តៅហ្នឹងគេថា យើងដឹងពត៌មានតក្លាមកគេថាកន្លែងសម្រាប់វៃមនុស្សដាក់ចោលតែវាជីកហើយមិនទាន់បានវៃ ។

ដានី៖ នៅមុខវត្តហ្នឹងតែម្តង?

វណ្ណៈ នៅមុខវត្តហ្នឹងតែម្តង មុខដើមចំបក់ហ្នឹង ។

ដានី៖ ចឹងវត្តហ្នឹងឃើញថ្មីស្អាតហ្នឹងទើបកសាងថ្មីទេ?

វណ្ណៈ ទើបកសាងថ្មីទាំងអស់បាទ ពីមុនមកអត់មានចឹងទេ មានតែកុដវែងទទឹងនិងមួយហើយវិហារចាស់មួយដែលបាក់បែកអស់ហើយទេ ។

ដានី៖ អរ ។

វណ្ណៈ ហើយខាងក្រោមហ្នឹងក៏ជញ្ជាំងបាំងជិតដែរ ជញ្ជាំងថ្មតែលោកវៃទម្លាយចេញសងខាងអស់ ។

ដានី៖ ចឹងកុដវែងហ្នឹងមានជញ្ជាំងបាំងជិតដែរ?

វណ្ណៈ បាទ!ហ្នឹងមានចំរឹងដែកចំរឹងអីបង្អួចអីហ្នឹង បង្អួចមានប៉ុន្មានប្រហែលជា៤ទៅ៥បង្អួច ។

ដានី៖ ចឹងមានបង្អួចបួនប្រាំ?

វណ្ណៈ បាទ ។

ដានី៖ ចឹងកាលពូឃើញអាកុដវែងហ្នឹងមានលក្ខណៈយ៉ាងម៉េច មានបង្អួចមានជញ្ជាំងយ៉ាងម៉េចខ្លះទៅពូ ពូអាចរៀបរាប់បានទេ?

វណ្ណៈ ជញ្ជាំងថ្ម បន្ទប់ចង្រ្កានដែកយើងធម្មតា បញ្ច្រេះៗ យើងបើកដូចជាទ្វារសាលារៀនចឹង ។

ដានី៖ បាទ ។

វណ្ណៈ ហើយខាងក្នុងក៏សុទ្ធតែគុក គុកគេដាក់ពីរជួរ ជួរខាងនេះគេដាក់ផ្ទុយគ្នា ។

ដានី៖ បាទ ។

វណ្ណៈ ហើយមនុស្សដើរប្រឡោះកណ្ដាល ។

ដានី៖ យ៉ាងម៉េចបានជាពូដឹងសុទ្ធតែគុក ចឹងម៉េចបានពូហ៊ានសន្និដ្ឋានអាហ្នឹងជាគុក?

វណ្ណៈ ចុះខ្ញុំចូលទៅគេឲ្យរើ ។

ដានី៖ គេឲ្យរើ?

វណ្ណៈ កាលហ្នឹងគេហៅលោកសង្ឃកាលហ្នឹងលោកគ្រូសង្ឃរាជ្យពីមុនមកនៅវត្តហ្នឹងពីមុន ឥឡូវប្អូនមកជួយរើឈើចេញក្នុងហ្នឹងមក ដល់ចឹងទៅឃើញចុះយើងធ្លាប់ឃើញសម័យប៉ុល ពតយើងដឹងនេះជាគុកតើនេះ ដល់ពេលនេះជញ្ជូនខ្នោះចេញមក ខ្នោះឈើទេ ។

ដានី៖ បាទ ។

វណ្ណៈ តែដល់មើលទៅឥដ្ឋការ៉ូកន្លែងខ្លះក៏មានឈាមជាមជាប់ណាស់ ។

ដានី៖ ចឹងកាលហ្នឹងពេលដែលពូចូលទៅដំបូង លោកតាសង្ឃរាជ្យឲ្យទៅជួយរើអីនេះ កាលហ្នឹងគេមានប្រាប់ថាគុកអីគេ កាលហ្នឹង?

វណ្ណៈ គេអត់មាននិយាយទេ គេអត់មាននិយាយរឿងគុកអីប្រាប់យើងទេ តែនេះយើងដឹងតែម្ដងចុះធម្មតាយើងឃើញគុកហ្នឹងក្ដាហ្នឹងគេលុងចឹង ។

ដានី៖ បាទ ។

វណ្ណៈ លុងសម្រាប់ដាក់ជើងហើយគេមានរនុកដាក់ពីលើមករួចចាក់សោ ។

ដានី៖ បាទ ។

វណ្ណៈ ហើយយើងធ្លាប់ឃើញនៅសម័យប៉ុល ពតយើងដឹងថាអាហ្នឹងគុកហើយសម្រាប់ដាក់មនុស្សយើងធ្លាប់ឃើញគេដាក់ប្អូនយើងអីហ្នឹងណាស់ ។

ដានី៖ បាទ ។

វណ្ណៈ បានយើងដឹងថាអាហ្នឹងគុក យើងសភាពឃើញឈាមអីជាប់ឥដ្ឋការ៉ូចឹងយើងជួយបោសរៀបចំទៅចាប់ផ្ដើមធ្វើតុអីដាក់រៀន ។

ដានី៖ ចឹងកន្លែងខ្នោះដែលពូឃើញគេដាក់ពីរជួរមានឈើមានរនុកសឹកខ្នោះហ្នឹង?

វណ្ណៈ បាទ ។

ដានី៖ នៅក្នុងកន្លែងសាលាឆាន់ហ្នឹង អាសាលា?

វណ្ណៈ នៅក្នុងអាសាលាវែងហ្នឹង ។

ដានី៖ អាសាលាវែងមួយហ្នឹង?

វណ្ណៈ បាទ ។

ដានី៖ មានតែមួយនិងទេ?

វណ្ណៈ មានតែមួយនិងទេ ។

ដានី៖ ចឹងកន្លែងផ្សេងអត់មានទេ?

វណ្ណៈ អត់មានទេ កន្លែងផ្សេងសុទ្ធតែកសាងថ្មីទាំងអស់ហ្នឹង មានតែចាស់មួយហ្នឹង ។

ដានី៖ ចឹងបើតាមពូស្មានមើលតើគុកខ្មោះហ្នឹងប្រហែលជាប៉ុន្មានទៅក្នុងមួយជួរៗពីរជួរហ្នឹង?

វណ្ណៈ មួយជួរហ្នឹងប្រហែលបានជា២០នាក់ ក្នុងមួយជួរ ។

ដានី៖ ចឹងក្នុងមួយជួរប្រហែលជា២០?

វណ្ណៈ បាទ ។

ដានី៖ ចឹងទាំងពីរជួរហ្នឹងប្រហែលជា៤០?

វណ្ណៈ បាទ ។

ដានី៖ ចឹងគុកហ្នឹងបើដាក់បានប្រហែលជា៤០អីទេ?

វណ្ណៈ ដាក់បានប្រហែលជា៤០ ។

ដានី៖ ចឹងពូមានឃើញខោអាវឬមួយសាកសពអីដែរ?

វណ្ណៈ អត់មានឃើញទេ សាកសពមានឃើញដូចខ្ញុំថាចឹងយើងទៅសម្អាតពលកម្មខាងក្រៅទៅឃើញ មានដាក់ច្រវ៉ាក់ខ្ញុំថាចំមនុស្សគេយកទៅសម្លាប់ចោលដាក់ច្រវ៉ាក់ចឹងណឹង ។

ដានី៖ ឃើញយ៉ាងម៉េច ពេលពូឃើញហ្នឹង?

វណ្ណៈ ឃើញច្រវ៉ាក់ដៃយើងហ្នឹង និយាយរួមដើមដៃយើងចឹងហើយមានច្រវ៉ាក់ចាក់ជាប់សោនេះ ។

ដានី៖ អរ!ចឹងពេលឃើញហ្នឹងស្ថានភាពសពហ្នឹងយ៉ាងម៉េច ដូចរបៀបថាពូឃើញហ្នឹង?

វណ្ណៈ ឃើញហ្នឹងនិយាយរួមនៅតែឆ្អឹងទេ ។

ដានី៖ បាទ!ឃើញតែឆ្អឹងទេ?

វណ្ណៈ ក្បាលមិនដឹងជាល្បើកល្បាញទៅណាអស់ហើយ ឃើញតែឆ្អឹងដៃហ្នឹងហើយឆ្អឹងខ្នងអីនៅ ។

ដានី៖ អឺ ។

វណ្ណៈ ធម្មតាយូរឆ្នាំទៅសត្វទាញកាយអីចឹងទៅ វាបែកខ្ញែកវាមិនបាននៅមូលល្អ ។

ដានី៖ បាទ ។

វណ្ណៈ៖ ប៉ុន្តែខាងក្រោមហ្នឹងមានដើមក្រូចប្រហែលជា១០០ដើម ប៉ុន្តែសាកសពទាំងអស់កប់តាមអន្លុងដើមក្រូចទាំងអស់ ។

ដានី៖ បាទ ។

វណ្ណៈ៖ ហើយពេលដែលខ្ញុំចូលមកក៏អត់ដឹងថាកន្លែងហ្នឹង សាកសពកន្លែងដើមក្រូចហ្នឹងថាជាកន្លែងខ្មោចដែរ តែមានគេផ្ដើលថាគេដើររកជីកមាស ជីកខ្មោចបានមាសហ្នឹង ។

ដានី៖ បាទ ។

វណ្ណៈ៖ មានថ្ងៃមួយគេផ្ដើលជីកម៉ាជីនាខាងក្រោមហ្នឹងគេជីកទាំងអស់ ដល់ពេលជីកទៅមានឃើញឆ្អឹងក្បាលខ្មោចហ្នឹងលោកក៏យកក្បាលខ្មោចមួយចំនួនប្រហែលមានតែ៣០មិនដឹងទេនៅកន្លែងចេតិយ៍ហ្នឹងណាស់ ។

ដានី៖ បាទ ។

វណ្ណៈ៖ អាហ្នឹងក្បាលប៉ុនៗនេះ ហើយគេផ្ដើលជីកឆ្អឹងមកលើគោគអស់ហើយ ហើយក្រោយមកទៀតដូចខ្ញុំថាចឹង ប្រហែលជា៨៥-៨៦ហ្នឹងអាហ្នឹងបើតាមខ្ញុំស្មានណាស់ ។

ដានី៖ បាទ ។

វណ្ណៈ៖ មានម្នាក់មកពីខេត្តកំពត ។

ដានី៖ បាទ ។

វណ្ណៈ៖ មកពីខេត្តកំពតហ្នឹងមកនិយាយទាក់ទងទំនាក់ទំនងជាមួយយើងហ្នឹង ឥឡូវខ្ញុំសូមបងឯងហូបបាយបានមួយពេលពីរពេលមកចាំខ្ញុំមានរឿងមួយនិយាយប្រាប់បងឯង ខ្ញុំថាប្រាប់ពីបញ្ហាអីកាលហ្នឹងខ្ញុំនៅផ្ទះថ្មីហើយកាលហ្នឹង ក៏គាត់ហូបបាយហើយគាត់និយាយថា ខ្ញុំកាលសម័យប៉ុល ពតខ្ញុំធ្វើមេខ្មែរក្រហមហើយគ្នាខ្ញុំពីរនាក់ ពីរនាក់ហ្នឹងសុទ្ធតែមេធំៗណាស់ ។

ដានី៖ អឺ ។

វណ្ណៈ៖ ហើយម្នាក់ហ្នឹងមុនខ្ញុំយកទៅសម្លាប់និងវាមានមាសជាប់ខ្សែចង្កេះវាហ្នឹង៨ជីឡឹង ហើយនិងចិញ្ចៀនពេជ្រមួយវង់ហើយពេលយកទៅវ៉ៃចោលហ្នឹង ខ្ញុំយកទៅវ៉ៃគ្នាពីរនាក់ហើយវាថាវាស់ ពីដើមដូងមុខមច្ចុរទៅវាស់ទៅ៧ជំហាន ។

ដានី៖ អឺ ។

វណ្ណៈ៖ វាស់ទៅ៧ជំហានទៅចំហ្នឹងជីកទៅ ដល់ពេលហ្នឹងមិនហ៊ានជីកថ្ងៃទៀត បបួលគ្នាជីកយប់ចាស់ៗគេទៅ តែខ្ញុំគេឲ្យទៅកាន់ពិល ។

ដានី៖ អឺ ។

វណ្ណៈ៖ កាន់ពិលដល់ពេលទៅក៏យប់ឡើងទៅ ថាច្បាស់ហើយខ្ញុំអត់មាននិយាយកុហក់បងឯងបើខ្ញុំអ្នកវៃផ្ទាល់តែម្ដង ។

ដានី៖ បាទ ។

វណ្ណៈ៖ វៃពីរនាក់តែខ្ញុំបាញ់ចោលម្នាក់ ព្រោះថាទៅគ្នាពីរនាក់ណាស់ ។

ដានី៖ អឺ ។

វណ្ណៈ៖ ដល់ពេលវាដឹងថា ជិតបែកហើយវាបាញ់ម្នាក់សម្លាប់ចោលវាទុកខ្លួនវា ប៉ុន្តែរបស់ហ្នឹងអត់មានបានទេ ដឹកឃើញដូចថាមែន ពេលបងឯងដឹកទៅដល់ឃើញក្បាលខៀវក្បាលរបស់អាហ្នឹងហើយ អាហ្នឹងក៏មិនមែនធម្មតាដែលកងទ័ពដែរ វានិយាយ ។

ដានី៖ បាទ ។

វណ្ណៈ៖ វាកងទ័ពដែលខ្ញុំសម្លាប់ហ្នឹង ហើយអាកងទ័ពនេះហ្នឹងក៏ខ្ញុំសម្លាប់ដែរ តែអាហ្នឹងទៅសម្លាប់ទាំងពីរនាក់ដល់ពេលសម្លាប់អាហ្នឹងហើយត្រូវបាញ់អាហ្នឹងចោលទៀត ពេលដឹកអាហ្នឹងទៅដែលមិនថាវាមិនទៅទេ យប់ហ្នឹងទៅ ទៅដល់ដឹកវាថាហ្នឹងហើយវាស់៧ជំហានក៏ចាប់ផ្ដើមដឹកទៅឃើញតែឆ្អឹងឃើញតែក្បាលតែមាសអត់ឃើញ បានវាឆ្ងល់ថាគិតទៅមាសចេះដើរអត់មានពីណាដឹងសោះពេលវាសម្លាប់ហ្នឹងអត់មានពីណាដឹងទេ វាដឹងតែពីរនាក់និងអាអ្នកងាប់ហ្នឹង បើអាអ្នកងាប់វាបាញ់ចោលបាត់ហើយមានពីណាដឹងទៀត ។

ដានី៖ អឺ ។

វណ្ណៈ៖ វាថាខ្សែចង្កេះ៨ជីឡើងហើយនិងចិញ្ចៀនពេជ្រមួយវង់ ។

ដានី៖ អឺ ។

វណ្ណៈ៖ វាថាទៅគាស់ដឹងតែឃើញហើយ វាប្រាប់ទៀតថាខោអាវទាហានគាស់ទៅឃើញខោអាវទាហានឃើញអីមែនតែពេល ឃើញក្បាលអីមែនគ្រាន់ថាមើលទៅកន្លែងចង្កេះអត់ឃើញ ។

ដានី៖ អត់ឃើញ?

វណ្ណៈ៖ អត់ឃើញអត់ឃើញវាថា នៅចង្កេះពេលសម្លាប់ហ្នឹងអាមួយអ្នកកប់ហ្នឹងវានៅកាន់គាំភ្លើងឈចឹងឃើញខ្សែចង្កេះវានៅដល់ពេលកប់ជិតអីហើយដល់ពេលបាន៧ទៅ៨ឆ្នាំបានវាមករកគាស់អត់ឃើញ ។

ដានី៖ ចឹងពូអាអ្នកដែលវាមកថាខ្លួនឯងជាប្រធានគុកកន្លែងហ្នឹងហើយសម្លាប់ហ្នឹង ថាមកគាស់មាសហ្នឹងគាត់ឈ្មោះអីទៅ?

វណ្ណៈ ខ្ញុំមិនបានស្គាល់ឈ្មោះដែរ ដឹងថាខេត្តកំពត ។

ដានី៖ ខេត្តកំពត?

វណ្ណៈ បាទ ។

ដានី៖ គេមានប្រាប់ថាតួនាទីវាធ្វើអី?

វណ្ណៈ ថាគេហ្នឹងជាកងទ័ពមេវរៈសេនាតូចប្រាប់ចឹង ។

ដានី៖ ប្រាប់ចឹងហើយគេគ្គាប់នៅគុកហ្នឹង?

វណ្ណៈ និយាយទៅវាគ្គាប់ចង់ម៉ាក្រុងហ្នឹងតែម្តង វាមិនមែនគ្គាប់តែមួយគុកហ្នឹងទេណាស់ តួនាទីគេគុកហ្នឹងក៏គេត្រូវចេញចូលសម្ងាប់អីណា ត្រូវសម្ងាប់អីគេមកត្រួតពិនិត្យមើលអ្នកណាចង់សម្ងាប់អីហ្នឹងគេជាអ្នកសម្រេចចឹងណាស់ ។

ដានី៖ អរ!អត់ដឹងឈ្មោះ?

វណ្ណៈ អត់ដឹង អត់ប្រាប់ឈ្មោះផង ។

ដានី៖ តែស្រុកកំណើតគេនៅកំពតស្រុកអីទៅ?

វណ្ណៈ ខ្ញុំអត់ដឹងដែរ ដឹងថាខេត្តកំពត ។

ដានី៖ គេមកគ្នាប៉ុន្មាននាក់?

វណ្ណៈ មកម្នាក់ឯង ។

ដានី៖ មកម្នាក់ឯង?

វណ្ណៈ បាទ ។

ដានី៖ ឆ្នាំប៉ុន្មាន?

វណ្ណៈ ដូចខ្ញុំថាដូចជាឆ្នាំ៨៦ហ្នឹង ។

ដានី៖ ឆ្នាំ៨៦?

វណ្ណៈ បាទ ។

ដានី៖ ចឹងពេលគេមកចឹងនៅពេលយប់ទៅដឹក?

វណ្ណៈ បាទ!ទៅដឹក ។

ដានី៖ គេមកហូបបាយផ្ទះពូ?

វណ្ណៈ បាទ!ដល់គេហូបបាយហ្នឹងរាល់ដងមិនដឹងជាហូបណាទេ តែដល់ថ្ងៃដឹកហ្នឹងថាមកជុំគ្នាដូចថាគេកំណត់គ្នាទៅដឹកមើល ។

ដានី៖ បាទ ។

វណ្ណៈ  របស់ហ្នឹង ក៏គេហៅទៅធម្មតាមនុស្សរចង់បាន ។

ដានី:  បាទ ។

វណ្ណៈ  ដូចខ្ញុំហ្នឹងគេឲ្យកាន់ពិលខ្ទើមខ្លាចខ្មោចចង់ងាប់ហ្នឹង កាន់ពិលចឹងគ្រាន់កាន់វៀងបញ្ឈពិលហ្នឹងគេថាកុំដាក់ភ្លឺខ្លាំងពេកដាក់ឲ្យគៀកអន្ទុងបន្តិចហើយខ្ញុំវាខ្ទើមខ្មោចហ្នឹង ហើយគេថាឯងបើសិនជាឲ្យលុយលឿនណាស់ ដល់ពេលចឹងខ្ទើមខ្ញុំថាខ្ញុំខ្ទើមណាស់ មិនឲ្យហឹចុះ ។

ដានី:  កាលហ្នឹងមានគ្នាប៉ុន្មាននាក់ជីកហ្នឹង ជីករណ្ដៅហ្នឹង?

វណ្ណៈ  ជីកហ្នឹងគ្នាទាំងអស់មាន៤នាក់ ។

ដានី:  ពូមានចាំឈ្មោះពីណាខ្លះ?

វណ្ណៈ  ម្នាក់ហ្នឹងឈ្មោះ បង វី រាល់ថ្ងៃគាត់នៅប្រទេសកាណាដានោះ ។

ដានី:  ចឹងវីរាល់ថ្ងៃគាត់ទៅប្រទេសកាណាដា?

វណ្ណៈ  បាទ ។

ដានី:  ត្រូវម៉េចជាមួយពូ?

វណ្ណៈ  ត្រូវជាបងប្អូនខាងម៉ាក់ ។

ដានី:  គាត់នៅភូមិហ្នឹងដែរ?

វណ្ណៈ  បាទ! នេះផ្ទះគាត់កាលពីមុន គាត់ផ្ទះខាងនេះតែគាត់ទៅនៅកាណាដា ។

ដានី:  ចុះពីណាទៀតក្រៅពីវីហ្នឹង?

វណ្ណៈ  ម្នាក់ទៀតឈ្មោះ តា យ៉ាន់តាមួយផ្ទះនៅលើនោះ គាត់ហ្នឹងឥឡូវអត់មានចាំស្មារតីបានទេគាត់ពិការហើយ ។

ដានី:  គាត់អាយុប៉ុន្មានហើយ?

វណ្ណៈ  តា ហ្នឹង៦០ហើយ ។

ដានី:  តែឥឡូវយ៉ាងម៉េច ឥឡូវគាត់និយាយអត់កើតទេ?

វណ្ណៈ  គាត់ឥឡូវគាត់និយាយអត់ដឹងមុខដឹងក្រោយ គាត់ធ្វេងសតិ្តអារម្មណ៍គាត់ចេះតែភ្លេចគាត់ហូបស្រាអីចឹងទៅបាទ ហើយណាមួយគាត់ឈឺចឹងគាត់ពោះវៀនបីបួនតង់នោះ ។

ដានី:  តា យ៉ាន់ផ្ទះគាត់នៅណា?

វណ្ណៈ  ផ្ទះគាត់នៅខាងលើនោះកន្លែងដើមស្វាយហ្នឹង ។

ដានី:  ពីណាទៀតបានបងវីនិងតា យ៉ាន់?

វណ្ណៈ  ហើយប៉ាខ្ញុំ ប៉ាខ្ញុំស្លាប់បាត់ហើយហ្នឹង ។

ដានី៖ ពូគាត់ឈ្មោះ ស៊ុនហ្នឹង?

វណ្ណៈ៖ បាទហើយខ្ញុំហ្នឹង ។

ដានី៖ ចឹងបួននាក់ទាំងពូ?

វណ្ណៈ៖ បាទ ។

ដានី៖ គ្នាបួននាក់ហ្នឹងហើយអ្នកនាំទៅហ្នឹងម្នាក់ទៀត?

វណ្ណៈ៖ បាទ!ដល់ដឹកអត់បានចឹងក៏គេទៅវិញទៅ គេថាមិនអស់ចិត្តទេ គេស្តាយគេអ្នកវ៉ៃខ្លួនគេ គេស្តាយ ។

ដានី៖ អឺ ។

វណ្ណៈ៖ ប៉ុន្តែកន្លែងវត្តហ្នឹងតាមមើលទៅមានកប់មាសច្រើនណាស់ ព្រោះអ្នកខ្លះមកបួសធ្វើជាលោកសង្ឃចឹងដល់ពេលនេះទៅ គេគាស់យកខ្លួនគេទៅ គេថាគេជាអ្នកសម្លាប់មនុស្សអីចឹងដែរ ។

ដានី៖ អឺ ។

វណ្ណៈ៖ កប់សម័យហ្នឹងដែលហ្នឹង ។

ដានី៖ ចឹង?

វណ្ណៈ៖ ដូនកាលកប់នៅកន្លែងយាយម៉ៅនេះមួយកេះ ហើយកន្លែងដើមចំបក់និងមិនតិចកេះទេ គេមកគាត់ពេលយប់យកទៅបាត់ ។

ដានី៖ ចឹងកន្លែងពូគាស់មិញហ្នឹងកន្លែងណាទីតាំងខ្ញុំមិនទាន់ច្បាស់?

វណ្ណៈ៖ ខាងក្រោមបច្ចារ ។

ដានី៖ ខាងក្រោមបច្ចារ អាបច្ចារចាស់មួយហ្នឹង?

វណ្ណៈ៖ អាបច្ចារគេវ៉ៃចោលថាចាស់ហ្នឹងបាទ ។

ដានី៖ អឺ!បច្ចារខាងក្រោមទៅប៉ុន្មានម៉ែត្រពីបច្ចារ?

វណ្ណៈ៖ និយាយរួមប្រហែលជា៧ម៉ែត្រទៅ ។

ដានី៖ ៧ម៉ែត្រហ្នឹងមិនជិតដល់ផ្លូវហើយ ជិតផ្លូវគេធ្វើថ្មីនោះ?

វណ្ណៈ៖ ជិតដល់ផ្លូវហ្នឹង១មុំជិតផ្លូវហ្នឹងតែម្តងបាទ ។

ដានី៖ គៀកផ្លូវហ្នឹងតែម្តង?

វណ្ណៈ៖ គៀកផ្លូវហ្នឹងតែម្តង ។

ដានី៖ ចឹងកាលពូដឹកហ្នឹងពូបានឃើញសាកសពហ្នឹងយ៉ាងម៉េច ស្ថានភាពពេលហ្នឹងពូអាចនិយាយ?

វណ្ណៈ៖ សពហ្នឹងនិយាយរួមធម្មតាគេវ៉ៃចោលគេមិនដែលរុំខ្ចប់ដូចយើងឲ្យយើងត្រឹមត្រូវទេ ។

ដានី៖ បាទ ។

វណ្ណៈ យើងទៅដល់ដីកទៅឃើញភ្លួយវាវែមនុស្សចោលចឹងវាដាក់ភ្លួយពីលើ ដូចអាប៉ុហ្នឹងថាចឹងឲ្យយើងកាប់កាយចឹងដល់ភ្លួយបនឯនដីកដល់ខ្មោចហើយ ដល់កាយទៅឃើញភ្លួយឃើញនេះមែនហើយឃើញស្បែកជើងកង់ឡានឃើញអីរូបរាងវាទាំងអស់ ។

ដានី៖ ចឹងមានឃើញខោអាវដែលអត់?

វណ្ណៈ ខោអាវឃើញ ខោអាវទាហាន ។

ដានី៖ ខោអាវទាហាន?

វណ្ណៈ ខោអាវទាហានប៉ុល ពតហ្នឹង ។

ដានី៖ ចឹងខោអាវទាហានចឹងអ្នកទោសហ្នឹងជាទាហានទេ?

វណ្ណៈ អ្នកទោសហ្នឹងជាទាហាន ទាហានហើយបានជាវាមានខ្សែចង្កេះហ្នឹងដល់ផងឡើងពាក់និងខ្លួនបែបមេគេមួយដែលហ្នឹង ដល់ពេលបីនាក់ហ្នឹងបែបវាមិនត្រូវគ្នាម៉េចថ្នាក់លើគេឲ្យការណ៍មកត្រូវសម្លាប់អាហ្នឹងចោលមួយ ។

ដានី៖ អឺ ។

វណ្ណៈ សម្លាប់អាហ្នឹងចោលមួយ អាមួយហ្នឹងវាលោភលន់បើទុកអាដៃគូរនិងទៀតរបស់អាងាប់និងមិនអញ ចឹងអញសម្លាប់ចោលទៀត ។

ដានី៖ អឺ!គេថាចឹង?

វណ្ណៈ បាទ!វាបាញ់ខ្លួនវាអាអ្នកបាញ់ហ្នឹងយកទៅបាញ់ណាខ្ញុំមិនបានដឹងទេ វាអត់និយាយទេវាគ្រាន់ថាវាបាញ់ចោលហើយអាមួយហ្នឹង ។

ដានី៖ ចឹងពេលពូដីកឆ្នាំ៨៦ហ្នឹងដូចថាពេលដីកទៅ មិញហ្នឹងថាខ្មឹមហ្នឹងនៅមានក្លិនមានអីទៀត?

វណ្ណៈ ដីកទៅខោអាវមនុស្សយើងឡើងខ្មៅឡើងខ្វាញ់ អាហ្នឹងយើងមើលពេលយប់ណាស់ ។

ដានី៖ បាទ ។

វណ្ណៈ ហើយឡើងធុំ អត់មានធុំអីធុំរបៀបដីវាអត់មានធំក្លិនស្អុយទេ ។

ដានី៖ បាទ ។

វណ្ណៈ ដូចដីដីធំក្លិនដេះអីហ្នឹងណាស់ ។

ដានី៖ បាទ ។

វណ្ណៈ វាទៅចឹងវិញ ។

ដានី៖ ចឹងបើតាមពូស្មានកន្លែងពូដីកហ្នឹងមានសាកសពច្រើនទេ?

វណ្ណៈ	សាកសពកន្លែងខ្ញុំហ្នឹងតែមួយទេ ។

ដានី:	ចឹងតែម្នាក់ទេ?

វណ្ណៈ	បាទ!តែម្នាក់ទេកន្លែងវាវៃចោលនេះ ។

ដានី:	បាទ ។

វណ្ណៈ	ប៉ុន្តែខាងក្រោយដីដែលគេលក់ធ្វើផ្ទះអីហ្នឹងច្រើនប្រហែលជាប្អូនដបខ្មោចដែរ ។

ដានី:	អរ ។

វណ្ណៈ	ប៉ុន្តែយើងមិនអាចទៅជីកហ្នឹងទេ ព្រោះយើងអត់មានគោលដៅយើងទៅជីកហ្នឹង ។

ដានី:	ចឹងផ្លូវមួយដែលចេញទៅហ្នឹងមានដើមឈើមានដើមអាកាស្យាអី?

វណ្ណៈ	អាកាស្យាហ្នឹង សុទ្ធតែអាកាស្យាទាំងអស់ពីមុនសុទ្ធតែខ្មោចហ្នឹង ។

ដានី:	ចឹងពីមុនកន្លែងអមផ្លូវហ្នឹងសុទ្ធតែខ្មោចទេ?

វណ្ណៈ	បាទ!និយាយរួមក្រោមគុម្ពឫស្សីហ្នឹង ។

ដានី:	ក្រោមគុម្ពឫស្សី?

វណ្ណៈ	បាទ!អាសាលាយាយមួយ តូបយាយប៉ុន្មានដែលសំណាក់ធម៌ខាងក្រោមនោះ ។

ដានី:	អរ ។

វណ្ណៈ	ខាងក្រោយតូបហ្នឹងសុទ្ធតែខ្មោចហើយហ្នឹង ។

ដានី:	ចឹងសុទ្ធតែខ្មោច?

វណ្ណៈ	តែឥឡូវគេគាស់មិនយកទៅណាទៅណីអស់ហើយ មិនដឹងថាខ្មោចប៉ុល ពតសម្លាប់ចោលឬមួយខ្មោចប្រជាជន ប្រជាជនកម្រមានកប់នៅហ្នឹងណាស់ ។

ដានី:	បាទ!ចឹងពូទៅជីកហ្នឹងជីកតែម្តងហ្នឹងឬមានពេលណាទៅជីកទៀត?

វណ្ណៈ	ជីកតែម្តងហ្នឹង ព្រោះខ្ញុំអ្នកខ្លាចខ្មោចមិនចង់បាន ដោយសារចាស់ៗថាឯងទៅគ្រាន់តែបញ្ចាំងពិលឲ្យ អញបានហើយ ។

ដានី:	បាទ ។

វណ្ណៈ	ហើយប៉ាខ្ញុំក្តួតចង់ងាប់ហ្នឹង ។

ដានី:	បាទ ។

វណ្ណៈ	ហើយតាហ្នឹងគ្រាន់តែនេះក្អួតមក ដល់មកផ្ទះវិញអត់បានហើយដែលាងសាប៊ូជិតមួយអាទិត្យមិនទាន់បាត់ផងវាខ្លាញ់ណាស់ ។

ដានី:	អឺ ។

វណ្ណៈ	ខ្ញាញ់មាំណាស់ ។

ដានីៈ	អឺ ។

វណ្ណៈ	ចុះមិនខ្ញាញ់បើគាត់រើសអាវមកគាត់ជជុះញីអាវខ្លាចវាធ្លាក់ទៅក្នុងអាវក្នុងខោហ្នឹង ។

ដានីៈ	បាទ!ចឹងអ្នកដែលជាប់ទោសហ្នឹងបើសិនជាពួកគិតមើលជាប្រជាជនឬមួយជាទាហានឬកងទ័ពខ្មែរក្រហម?

វណ្ណៈ	បើតាមធ្វើការសន្និដ្ឋានប្រហែលជាប្រជាជនមានតិចណាស់ មានទ័ពយើងឃើញដូចថាវាសម្លាប់ហ្នឹងយើងដឹងទៅតាមហ្នឹងវិញ ។

ដានីៈ	បាទ ។

វណ្ណៈ	មានតែទ័ពទេ ដូចថាទ័ពមានកំហុសខុសឆ្គងអីហ្នឹង ដូចជាខូចសីលធម៌អីហ្នឹងវាយកមកដាក់និងទៅ ។

ដានីៈ	ចឹងកាលមកដំបូងពូថាលោកពឹងឲ្យជួយសម្អាតអីហ្នឹង កាលហ្នឹងពូសម្អាតប៉ុន្មានថ្ងៃហើយមានគ្នាប៉ុន្មាននាក់?

វណ្ណៈ	សម្អាតហ្នឹងសម្អាតតែមួយថ្ងៃព្រោះបន្ទប់ហ្នឹងតែប៉ុណ្ណឹងតែវាវែង ។

ដានីៈ	គ្នាមានប៉ុន្មានកាលទៅសម្អាតហ្នឹង?

វណ្ណៈ	គ្នាប្រហែលជានិយាយសិស្សមួយថ្នាក់ទៅទាំងអស់ ប្រហែលជាង១០នាក់ ។

ដានីៈ	ជាង១០នាក់កាលហ្នឹងពូនៅរៀនដែរ?

វណ្ណៈ	បាទ!នៅរៀនហើយមានគ្រូពីរនាក់ គ្រូពីរនាក់ហ្នឹងគ្រូស្រីម្នាក់គ្រូប្រុសម្នាក់ ។

ដានីៈ	គ្រូហ្នឹងឈ្មោះអីខ្លះ?

វណ្ណៈ	គ្រូប្រុសឈ្មោះធី តែគ្រូស្រីហ្នឹងមិនដឹងជាឈ្មោះអីទេ ខ្ញុំអត់ស្គាល់ឈ្មោះ ។

ដានីៈ	ឥឡូវគាត់នៅទេ?

វណ្ណៈ	និយាយរួមស្លាប់អស់បាត់ហើយ គាត់និងគាត់នៅភ្នំពេញនោះ ។

ដានីៈ	ចឹង?

វណ្ណៈ	បាទ!គាត់ជាអ្នកកំណើតនៅភ្នំពេញ ។

ដានីៈ	កាលហ្នឹងពូអាយុប្រហែលជាប៉ុន្មាន?

វណ្ណៈ	កាលហ្នឹងខ្ញុំប្រហែលជា១៣-១៤ឆ្នាំហ្នឹង ។

ដានីៈ	បាទ!ចឹង៧៩ហ្នឹងបណ្តោយ?

វណ្ណៈ	បាទ ។

ដានី៖ ចឹងកាលហ្នឹងពូមានឃើញខ្មោះឃើញមានស្នាមឈាមអីហ្នឹង?

វណ្ណៈ បាទ!ស្នាមឈាមជាប់នៅឥដ្ឋការ៉ូ ឥដ្ឋការ៉ូក្រហមយើងហ្នឹង ។

ដានី៖ ចឹងឃើញតែខ្មោះនិងឈាមទេអត់មានឃើញអីទៀតទេ?

វណ្ណៈ អត់មានឃើញស្អីទេ តែកន្លែងហ្នឹងសុទ្ធតែពីងពាងនិយាយរួមគុកហ្នឹងសុទ្ធតែពីងពាង ។

ដានី៖ បាទ ។

វណ្ណៈ ពីងពាងព័តលើខ្មោះលើអីហ្នឹង ។

ដានី៖ ឃើញមានរូបថតរូបអីទេ?

វណ្ណៈ អត់មានទេ ។

ដានី៖ អត់មានទេ?

វណ្ណៈ បាទ!អាហ្នឹងមិនមែនជាគុកធំដុំអី ។

ដានី៖ ចឹងកន្លែងដើមព្រីងមុខពូថាជីករណ្ដៅអី រណ្ដៅហ្នឹងទំហំប៉ុណ្ណាទៅ?

វណ្ណៈ រណ្ដៅហ្នឹងដូចខ្ញុំថាហ្នឹង ទំហំប៉ុនមុខផ្ទះហ្នឹង និយាយប្រហែលជា១០ម៉ែត្របួនជ្រុង ។

ដានី៖ ជំរៅទៅ?

វណ្ណៈ ជំរៅជ្រៅណាស់ ជំរៅមើលទៅប្រហែលជា៧ទៅ៨ម៉ែត្រដឹង ។

ដានី៖ ជំរៅចេះ?

វណ្ណៈ បាទ!លេងជីក«អ្នកជិតខាងនិយាយថា តិចលោរណ្ដៅគ្រាប់អាបេជំនាន់៧៥ហ្នឹង» វណ្ណានិយាយវិញថា អត់ទេរណ្ដៅប៉ុល ពតជីក ។

ដានី៖ ប៉ុល ពតជីក?

វណ្ណៈ បាទ!ប៉ុល ពតជីក ជីកកាយទាំងថ្មដាឡើងទៀត អាហ្នឹងចេះតែឮសួរគ្រាមគេគៗគ្នាមកថាគេជីកសម្រាប់ទុកសម្លាប់មនុស្សអ្នកខុសៗនៅក្នុងក្រុងគេមិនបញ្ជូនទៅណាគេវ៉ៃកប់សម្លាប់នៅហ្នឹងតែម្ដង ។

ដានី៖ ចឹងពូកាលសម័យបីឆ្នាំហ្នឹងអត់មានប្រជាជននៅក្នុងក្រុងហ្នឹងទេ?

វណ្ណៈ នៅមានឈ្មោះ តា ប៊ិចមួយ តា ប៊ិចហ្នឹងអាពតវាដាក់ទេ ផ្ទះគាត់ផ្ទះនេះតែគាត់ស្លាប់បាត់ហើយ មានតែតាហ្នឹងមួយទេ តាហ្នឹងដោយសារអីដោយសារអាពតវាទុក វាទុកតាហ្នឹងចេះតភ្លើង បច្ចេកទេសគាត់ខាងរដ្ឋករទឹកដែលតែគាត់ចេះតភ្លើង ហើយឃើញគាត់ចាស់ហើយអត់ប្រពន្ធទៀតទុកតាហ្នឹងមួយ ។

ដានី៖ ទុកឲ្យនៅណា?

វណ្ណៈ	នៅហ្នឹងនៅកន្លែងម៉ាស៊ីនហ្នឹងម៉ាផ្ទះក្រោមនេះ ។

ដានី៖	អ ។

វណ្ណៈ	ឥឡូវផ្ទះហ្នឹងវារុះរើអស់ហើយ ។

ដានី៖	នៅតែគាត់មួយ?

វណ្ណៈ	នៅតែគាត់មួយ ។

ដានី៖	គាត់ស្លាប់ឆ្នាំណា?

វណ្ណៈ	គាត់ស្លាប់ប៉ុន្មានឆ្នាំហើយ គាត់ស្លាប់យូរដែលហើយស្លាប់ជាង១០ឆ្នាំហើយតាហ្នឹង ។

ដានី៖	ចឹងស្លាប់ជាង១០ឆ្នាំហើយ?

វណ្ណៈ	បាទ ។

ដានី៖	គេទុកគាត់មួយ?

វណ្ណៈ	គេទុកគាត់សម្រាប់ឲ្យតភ្លើង ។

ដានី៖	ក្រៅពីហ្នឹងអត់មានទេ?

វណ្ណៈ	អត់មានទេ គេបញ្ជូនចេញទាំងអស់ អត់មានទុកទេ មានតែតាហ្នឹងមួយតាហ្នឹងទុកបានយូរទៀតទុកដល់រំដោះហើយតាហ្នឹងនៅហ្នឹងទៀត ។

ដានី៖	អឺ ។

វណ្ណៈ	បើតាហ្នឹងនៅគាត់ដឹងប្រវត្តិតាហ្នឹង មេប៉ាខ្ញុំទៀត ។

ដានី៖	ចឹង?

វណ្ណៈ	បាទ!គាត់ខាងបច្ចេកទេស ។

ដានី៖	ចឹងកាលហ្នឹងគេដឹងថាកងទ័ពហ្នឹងកងពលយ៉ាងម៉េចកងទ័ពកងពលណា?

វណ្ណៈ	មិនដឹងថាខាងណាខាងណី យើងមិនបានដេញដោលសួរអីទេ យើងគ្រាន់មកឃើញភិនភាគហ្នឹង ។

ដានី៖	បាទ!ចឹងពូថាឃើញឆ្អឹងឃើញសាកសពជាប់ខ្នោះហ្នឹងឃើញនៅម្តុំណាហ្នឹង?

វណ្ណៈ	ឃើញនៅម្តុំនិយាយរួមគេធ្វើចេតិយ៍ ៧៩ហ្នឹងចេតិយ៍ដូចវិមានឯករាជ្យហ្នឹងនៅមុខហ្នឹងចេតិយ៍ធំហ្នឹង ។

ដានី៖	ចេតិយ៍ធំហ្នឹង?

វណ្ណៈ	ចេតិយ៍ធំរូបវិមានឯករាជ្យហ្នឹង នៅហ្នឹងឥឡូវគេធ្វើចេតិយ៍ពីលើហើយហ្នឹង ។

ដានី៖	សាកសពគេទុកហ្នឹងឬមួយមានគេប្រមូលយកទៅណាដែរ?

វណ្ណៈ	តែនេះគេប្រមូលចេញយកទៅណាទៅណីអស់ហើយ ។

ដានី៖	ចឹងដូចថាឈាមប្រឡាក់ឥដ្ឋអីហ្នឹងគេធ្វើម៉េចទៅពូអ្នកលាង?

វណ្ណៈ	លាងពួកសិស្សៗទាំងអស់ហ្នឹងដុសទឹកមកលាងជូតការ៉ូអីទៅ ។

ដានី៖	ចឹងជាប់តែការ៉ូជញ្ជាំងអីអត់ទេ?

វណ្ណៈ	អត់មានជាប់ជញ្ជាំងទេ ជាប់តែការ៉ូ ។

ដានី៖	អឺ ។

វណ្ណៈ	តែយើងមើលទៅឃើញឈាមកកនៅហ្នឹង ចុះធម្មតាវាយូរទៅនៅខ្មៅឡើងខ្មៅ ។

ដានី៖	អរ ។

វណ្ណៈ	ហើយយើងឃើញខ្នោះឃើញអី គេវ៉ៃប្រហែលជាបែកឈាមហូរពេញហ្នឹងហើយ ។

ដានី៖	ចឹងយើងលាងតែមួយថ្ងៃលាងហើយដាក់តុដាក់អីកន្លែងក្រោមឆាន់ហ្នឹងធ្វើសាលារៀនទៅ?

វណ្ណៈ	សាលារៀនដាក់ក្ដាខៀនហ្នឹងយើងមាត់ទ្វារមួយចេះយើងចូលមកមើលឃើញ មើលពីកើតមក ។

ដានី៖	រៀនហ្នឹងថ្នាក់ទីប៉ុន្មានខ្លះ?

វណ្ណៈ	ចាប់ផ្ដើមមុនដំបូងថ្នាក់ទី១ ។

ដានី៖	ថ្នាក់ទី១?

វណ្ណៈ	ថ្នាក់ទី១ ប៉ុន្តែរៀនអក្សរជ្រៅណាស់ រៀនអក្សរប្រកបសុទ្ធអ្នកចេះខ្លះៗពីហ្នឹងមក យើងមិនមែនរៀនស្រះ«អ»ស្រះ«អា»ណា ។

ដានី៖	ចឹងពូអ្នកដែលថាមកពីកំពតអ្នកដែលថាមកដឹកកំណាប់អីហ្នឹងចឹងពេលដែលយប់ហ្នឹងដឹកតែមួយយប់ហ្នឹងទេ?

វណ្ណៈ	ដឹកតែមួយយប់ហ្នឹងដឹកអត់បាន ។

ដានី៖	ដឹកប្រហែលម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន?

វណ្ណៈ	ដឹកម៉ោង៧ចាប់ផ្ដើមទៅហើយ ។

ដានី៖	ចឹងម៉ោង៧?

វណ្ណៈ	បាទ!ដឹកប្រហែលជាមួយម៉ោង ។

ដានី៖	ដឹកប្រហែលជាមួយម៉ោង?

វណ្ណៈ	បាទ ។

ដានី៖	ចឹងមួយម៉ោងរកអត់ឃើញចឹងយ៉ាងម៉េចទៅ?

វណ្ណៈ ក្រអត់ឃើញយើងកប់សាកសពហ្នឹងវិញទៅ ។

ដានីៈ ចឹងអ្នកហ្នឹងគេមកផ្ទះជាមួយពីវិញឬមួយគេទៅណា?

វណ្ណៈ គេទៅផ្ទះគេវិញ ។

ដានីៈ ទៅទាំងយប់ហ្នឹង?

វណ្ណៈ គេទៅស្នាក់នៅផ្ទះបងប្អូនគេត្រង់ម្តុំខុតុនិយម ។

ដានីៈ ចឹងគេអត់មានត្រឡប់មកវិញទេ?

វណ្ណៈ អត់មកវិញទេ ។

ដានីៈ គេមាននិយាយអីទៀតដែលអត់?

វណ្ណៈ ចុះបើអត់ឃើញទាំងអស់គ្នា វាថាមិនអស់ចិត្តតែម្តងចង់តែកាប់កាយទៀតខ្ញុំខ្ជិលដងថាចង់បានអីទេ តែរកមិនឃើញចប់ហើយកុំប្រាប់ផ្ទាលនាំអត់ងងុយចេះតែថាចឹង ។

ដានីៈ ចឹងក្រោយមកគេមានទៅជីកទៀតដែលអត់?

វណ្ណៈ អត់មានទេ ក្រោយមកទៀតដីម្តុំហ្នឹងអាត្រាកគេភ្ជួរដាំដើមអាកាស្យាទៅ ។

ដានីៈ ចឹងគាត់ហ្នឹងម៉េចក៏ហ៊ានម៉េះប្រាប់គេថាជាមេនៅហ្នឹង គាត់អ្នកសម្លាប់អ្នកអីចឹងគាត់អត់ខ្លាចទេចឹង?

វណ្ណៈ គាត់ខ្លាចដែលហ្នឹងគាត់មកហ្នឹង គាត់មកលួចៗចឹងគាត់មានហ៊ានចេញមុខឆ្អែកឆ្ងាចមិនឲ្យយើងដឹងវែងឆ្ងាយគ្រាន់តែមកដល់ប្រាប់យើងនិយាយចឹង គាត់ចង់បានពេកហើយ ។

ដានីៈ អឺ ។

វណ្ណៈ ម៉ាហ៊ីហ្នឹងមិនផ្អើលមនុស្សមកជីក ឲ្យតែឮសូរ្យថាសពប៉ុល ពតគេរើចោលកន្លែងណាគេជីករប៉ើករបាញហើយ ។

ដានីៈ ចឹងប្រធានគុកអីហ្នឹងពូមានដែលឮគេនិយាយអីទេ?

វណ្ណៈ អត់ទេ ។

ដានីៈ ចឹងចាស់ៗដែលដឹងរឿងដូចពូដែលមិញ តា យ៉ាន់មិញថាគាត់វង្វេង?

វណ្ណៈ បាទ ។

ដានីៈ ចឹងមានពីណាផ្សេងទៀតដែរ?

វណ្ណៈ អត់មានពីណាផ្សេងទៀត ព្រោះអ្នកជីកសពហ្នឹងមានតែខ្ញុំប៉ុន្មាននាក់ហ្នឹង ។

ដានីៈ ចឹងចាស់ៗផ្សេងទៀតដែលមក៧៩ជាមួយពូមាននៅរស់ដល់រាល់ថ្ងៃហ្នឹងទេ?

វណ្ណៈ ស្លាប់អស់ ។

ដានី៖ ចឹងស្លាប់អស់ហើយ?

វណ្ណៈ បាទ ។

ដានី៖ ចឹងខ្ទង់អាយុ៦០ជាង៩០ដូចអី?

វណ្ណៈ ខ្ទង់៦០ជាងហ្នឹងតា មឿនហាទើបស្លាប់ប៉ុន្មានទៅពោធិសាត់ ស្លាប់នៅពោធិសាត់ ។

ដានី៖ ចឹងអត់មានចាស់ៗណាដែលដឹងរឿងហ្នឹង?

វណ្ណៈ អត់មានទេ ស្លាប់អស់ហើយ មានតែខ្ញុំធ្លាប់ដឹងប្រវត្តិតាំងពីឪពុកយើងមកក្រោពីហ្នឹងចប់ហើយ ។

ដានី៖ ចឹងវត្តហ្នឹងគេសាងសង់ឆ្នាំណា សាងសង់ឃើញថ្មីឃើញធ្វើវិហាថ្មីសាងសង់អី?

វណ្ណៈ វត្តហ្នឹងខ្ទង់៨០ជាង«អ្នកជិតខាងនិយាយ កាលខ្ញុំនៅធ្វើចូល៨៥-៨៦ហើយ ព្រោះ៨៦មកដល់ខ្ញុំវែដញ្ញាំងវែអីចាប់ផ្ដើមធ្វើ» ។

ដានី៖ ចឹងចាប់ផ្ដើមធ្វើឆ្នាំ៨៥-៨៦ហើយ?

វណ្ណៈ បាទ ។

ដានី៖ ចឹងកាលដែលពូទៅជីកសពហ្នឹងគេមិនទាន់?

វណ្ណៈ គេមិនទាន់ធ្វើទេ ។

ដានី៖ ចឹងគេមិនទាន់ទេ?

វណ្ណៈ មានវិហាចាស់ហ្នឹងលេចមុខលេចក្រោយហ្នឹង ហើយក៏គ្មានរបងដែលមានតែដើមគគីរហ្នឹងជារបងហើយហ្នឹង មានតែដើមគគីរដូចយើងបោះព្រំចឹងណាស់ ។

ដានី៖ បាទ ។

វណ្ណៈ មានដើមគគីរឃើញប៉ុន្មានប៉ុណ្ណឹងហើយ ។

ដានី៖ បាទ ។

វណ្ណៈ ហើយប៉ាខ្ញុំពីជំនាន់មុនកាលជំនាន់សម្ដេចហ្នឹងទឹកន្លែងវត្តហ្នឹងកកើតមុនជំបូងសម្ដេចសង្ឃបង្កើតហ្នឹងគាត់បានរៀនបើកឡានគាត់ជីកដីយកមកចាក់វត្តហ្នឹងថយបុករបងវត្តបាក់ទៀតជងប្រវត្តិគាត់និយាយប្រាប់ណាស់ ។

ដានី៖ បាទ!គាត់និយាយចឹង?

វណ្ណៈ បាទ ។

ដានី៖ ចឹងពូវត្តហ្នឹងមានដែលពីណាមកស្រាវជ្រាវមកសួរនាំទាក់ទងរឿងគុករឿងអីទេ?

វណ្ណៈ  ឃើញមានអង្គការមួយចំនួនមកសួរដែរ  មកសួរថាមិនសូវនេះគេគ្រាន់តែមកសួរៗដើមហេតុតិចតួចអត់មានពីណាស្គាល់ គេទៅគេខ្ជិលយកពត៌មានអី ។

ដានីៈ  ចឹងគេអត់មានដែលមកសម្ភាសសួរនាំដូចខ្ញុំចឹងទេ?

វណ្ណៈ  អត់ទេ ព្រោះល្មមៗក៏ខ្ញុំខ្ជិលដែលព្រោះថា ខ្ញុំខ្ជិលនិយាយវែងឆ្ងាយ ។

ដានីៈ  បាទ ។

វណ្ណៈ  បើសួរចំខ្ញុំ ខ្ញុំចេះតែនិយាយទៅបើថា បើសួរអ្នកផ្សេងសួរអត់ដឹង ។

ដានីៈ  បាទ ។

វណ្ណៈ  “អ្នកជិតខាងនិយាយថា អ្នកដែលដឹងគោលៗមានតែគាត់ ខ្ញុំមកគ្រាន់តែដឹងល្បៀងៗ” ។

ដានីៈ  ចឹងកាលមុនគេមានតាំងឆ្អឹងក្បាលខ្មោចអីគេមានធ្វើប្រមូលទុកដែលអត់?

វណ្ណៈ  លោកប្រមូលទុកច្រើនដែលតាំងពិណ៌តាំងអីគេធ្វើបុណ្យអត្តឃាតអីចឹង ។

ដានីៈ  បាទ ។

វណ្ណៈ  ធ្លាប់ធ្វើដែលប៉ុន្តែសាកសពមានអន្ទុងលោកទុកនៅបាតក្រោមយ៉ាងម៉េចចឹង“អ្នកជិតខាងនិយាយ កាលហ្នឹងជំនាន់ តាអឹ” វណ្ណានិយាយវិញ មិនមែនទេ ជំនាន់តាអឹហ្នឹងធ្វើ ។

ដានីៈ  ចឹងសង្ឃរាជមុនលោកតា អឹ?

វណ្ណៈ  ប៉ុន្មានសង្ឃរាជនោះបីបួនសង្ឃរាជនោះវត្តហ្នឹង ។

ដានីៈ  អរ ។

វណ្ណៈ  “អ្នកជិតនិយាយថា លោកតាអឹហើយបានលោកតា នន់នោះ” វណ្ណានិយាយវិញ មុនលោកតាអឹមានលោកស្អីមួយទៀតលោកតា ហៃ អីចេះមិនដឹងខ្ញុំមិនសូវចាំច្បាស់ព្រោះសង្ឃរាជមានច្រើនដែលណាស់ ។

ដានីៈ  បាទ!ចឹងសាកសពហ្នឹងយ៉ាងម៉េចគេដាក់ក្នុងរណ្តៅឬមួយយ៉ាងម៉េច គេលើកយកមកហើយគេធ្វើស្តូបអីដាក់?

វណ្ណៈ  គេដាក់គ កាលមុនចេតីយ៍ហ្នឹងមិនមានសពដាក់ច្រើនដូចរាល់ថ្ងៃទេ ចឹងណាស់ ។

ដានីៈ  បាទ ។

វណ្ណៈ  គេដាក់ក្បាលខ្មោចហ្នឹង  កាលហ្នឹងចេតីយ៍ដែលដាក់នៅមុខកន្លែងព្រះអង្គ“អ្នកជិតខាងនិយាយថាហ្នឹងហើយក្បាលខ្មោចហ្នឹងគេយកមកដាក់តម្រៀបតើ” វណ្ណានិយាយវិញ  ព្រះអង្គដែលចូលនិពាន្ធរាល់ថ្ងៃហ្នឹងមុននេះហ្នឹង ។

ដានីៈ  អរ ។

វណ្ណៈ	ដាក់នៅកន្លែងហ្នឹង ចេតីយ៍អែបហ្នឹង ។

ដានី៖	ចឹងក្បាលខ្មោចហ្នឹងបាត់តាំងពីកាលណាមក?

វណ្ណៈ	ក្បាលខ្មោចហ្នឹងបាត់មុនហ្នឹងបន្តិច ប្រហែលជាគេដាក់នៅខាងក្រោមដងមិនដឹង នៅខាងក្រោមហ្នឹងមានរណ្ដៅមួយ មានរណ្ដៅនៅខាងចេតីយ៍ធំហ្នឹងណាស់ ចេតីយ៍រួមរាល់ថ្ងៃហ្នឹងមានគេជីកប្រឡោះមួយប៉ុននេះបួនជ្រុងណាស់ ហើយមានគំរបគេគ្របបែបគេដាក់នៅក្នុងបាតក្រោមហ្នឹង«អ្នកជិតខាងនិយាយថា បើយាយពៅគាត់ដឹង ព្រោះយាយពៅគាត់នៅចេតីយ៍ក្បាលខ្មោចហ្នឹង» ។

ដានី៖	យាយពៅណាទៅ?

វណ្ណៈ	យាយពៅយាយជីនៅខាងក្រោម ។

ដានី៖	ចឹងទើបបាត់ថ្មីៗហ្នឹងឬមួយបាត់យូរហើយ?

វណ្ណៈ	បាត់យូរដែលហើយ ប៉ុនតែខ្ញុំនៅរត់ម៉ូតូចុះឡើងហ្នឹងតែខ្ញុំវាមិនបានតាមដានឆ្អឹងអីគេហ្នឹងទុកដាក់ណា យើងមិនសូវយកចិត្តទុកដាក់ ។

ដានី៖	ចឹងលោកសង្ឃរាជរាល់ថ្ងៃហ្នឹងមិនទាន់ទេចឹង?

វណ្ណៈ	ទាន់អារឿងក្បាលខ្មោចហ្នឹង ជំនាន់ហ្នឹងលោកទាន់ហើយលោកដឹង ។

ដានី៖	លោកគ្រូសង្ឃរាជរាល់ថ្ងៃឈ្មោះអីគេ?

វណ្ណៈ	គុណ រ៉ែន ។

ដានី៖	មូល រ៉ែន?

វណ្ណៈ	ហ្នឹងហើយ ។

ដានី៖	ចឹងសង្ឃរាជមុនដំបូងបំផុតព្រះនាមអីទៅ កាលពី៧៩មក?

វណ្ណៈ	ស្អីទេ វាច្រើនតែខ្ញុំមិនចាំ ខ្ញុំចាំតែតា អឹុ ។

ដានី៖	ចឹងតាអឹុហ្នឹងកាលជំនាន់ណាពីឆ្នាំណាដល់ឆ្នាំណា?

វណ្ណៈ	វាមិនបានគិតរឿងឆ្នាំ កាលហ្នឹងមានតែតា អឹុហ្នឹងមុនគេហើយ ។

ដានី៖	ចឹងពេលដែលពូទៅគាស់អីហ្នឹងតា អឹុនៅសង្ឃរាជ?

វណ្ណៈ	ហ្នឹងហើយតា អឹុហ្នឹងនៅទេ «អ្នកជិតខាងនិយាយថា ចឹងគាត់តាំងពី៧៩» វណ្ណានិយាយវិញ គាស់អាហ្នឹងហើយខាងមុខវិហារទៀត មុខវិហារហ្នឹងមានគេអ្នកផ្សេងមកគាស់ គេថាកប់មាសនៅហ្នឹងប៉ុន្មាន បានគេឲ្យពត៌មានមកត្រួសៗទេណាស់ ។

ដានី៖	បាទ ។

វណ្ណៈ ថាមាននៅមាត់ជណ្ដើរហ្នឹងប៉ុន្មានកេះនោះ ។

ដានី៖ បាទ ។

វណ្ណៈ ប្អូនប្រាំកេះនោះហើយមានតែប៉ាខ្ញុំហ្នឹងគាត់ជិតដិតជាមួយសង្ឃរាជ្យហ្នឹងទៅថ្វាយបង្គំសង្ឃរាជ្យហ្នឹងថាឥឡូវ ករុណាសូមគាស់មាសនិយាយត្រង់ៗ លោកថាគាស់អីគាស់ទៅប៉ុន្តែបានឲ្យអញពាក់កណ្ដាលអញធ្វើបុណ្យទាន ហើយគាស់ហ្នឹងពួករដ្ឋករទឹកហ្នឹងទៅគ្នាប្អូនដបម្ភៃនាក់ ។

ដានី៖ បាទ ។

វណ្ណៈ ជីកនៅពេលយប់ទេណាស់ ។

ដានី៖ បាទ ។

វណ្ណៈ ទៅដល់ជីកអស់រលើងមុខជណ្ដើរហ្នឹងលោកថា ពួកឯងហ្នឹងមកបំផ្លាញហើយណា ក្រហូងដីអស់រលីងកុំឲ្យតែបានអីបន្តិច ។

ដានី៖ ចឹងអត់មានបានអី?

វណ្ណៈ អត់មានបានអី លោកឲ្យលុបវិញទៅ ។

ដានី៖ បាទ ។

វណ្ណៈ ប្រវត្តិហ្នឹងខ្ញុំចាំច្បាស់ ។

ដានី៖ បាទ ។

វណ្ណៈ "អ្នកជិតខាងនិយាយថា ក្បាលខ្មោចហ្នឹងប្រហែលជា៩០ដាងហើយ" វណ្ណានិយាយវិញថា ក្បាលខ្មោចហ្នឹងក្បាលធំៗណាស់ប៉ុនៗនេះ មានក្បាលហ្នឹងនិងឆ្អឹងដៃ ។

ដានី៖ ចឹងឪពុកពូគាត់ទៅគាស់ច្រើនដងដែលចឹង?

វណ្ណៈ ពីរដងដូចថាគេហៅទៅហ្នឹង ។

ដានី៖ ប៉ុន្តែអត់ដែលបានអីទេ?

វណ្ណៈ អត់ដែលបានទេ យើងគ្មានសំណាង មានកេះនៅមុខយាយម៉ៅហ្នឹងតាមដីងមកបួសលោក តែណឹងមិនដឹងជាឋានៈគេស្អីយើងអត់ដឹង មកបួសលោកដល់ពេលហើយគេថារបស់គេកប់ទុក ដាក់ការ៉ូមុខយាយម៉ៅហ្នឹងមួយកេះដល់ពេលបួសចឹងទៅ ដល់ពេលថ្ងៃកំណត់គេសឹកគេ គេ សឹកគេយកទៅ គេទៅធ្វើប៉ូលីសបណ្ដោយទៅមានពីណាហ៊ានធ្វើអីគេ ។

ដានី៖ អឺ ។

វណ្ណៈ ធ្វើមេប៉ូលីសទៀត ។

ដានី៖ ធ្វើមេប៉ូលីសឈ្មោះអីគេ?

វណ្ណា: អត់ស្គាល់ឈ្មោះដែរ គ្រាន់តែដឹង ។

ដានី: ចឹងគាត់មកបួសហ្នឹងដែលគេស្គាល់ទេអី?

វណ្ណា: «អ្នកជិតខាងនិយាយថា នៅពាក្យចាមអារាមគេថានៅច្រើនណាស់ មានអ្នកមកលួចគាស់អីតែរកមិនឃើញ» ។

ដានី: ចឹងខ្ញុំដូចជាអស់សំនួរអីត្រូវសួរនាំពូហើយ ពូមានអីចង់បន្ថែមអ៊ីដែលខ្ញុំមិនទាន់បានសួរនាំពូ?

វណ្ណា: ទេ អត់មានសំនួរបន្ថែមទៀតទេ ចប់ត្រឹមហ្នឹងហើយ ។

ដានី: ចឹងមកដល់សព្វថ្ងៃនេះពូមានដែលតាមដានដឹងរឿងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែរ?

វណ្ណា: ខ្ញុំមើលតាមទូរទស្សន៍ចឹងដែរ គេដាក់ឈុតរឿងកាត់ក្ដីទៅខ្ញុំមើលមួយឈុតបន្តិចហ្នឹង ។

ដានី: ពូមានដឹងថាកាត់ទោសហ្នឹងដំណើរការដល់ណាហើយ ពូមានដែលតាមដានទេ?

វណ្ណា: យើងមើលមិនបានចប់ចុងចប់ដើម ជួនកាលចាប់ផ្ដើមមើលចាប់ផ្ដើមផ្សាយចឹងទៅ កូនហៅទៅនេះទៅមិញហ្នឹងកំពង់តែបើកមើលបន្តិចកំពង់ដល់ពេលហ្នឹងហៅមកបងឯងវិញទៅចប់ ។

ដានី: ចឹងកាត់ទោសឌុចអីហ្នឹងពូមានដែលដឹងទេ?

វណ្ណា: បាទ! បានឃើញដែរ ។

ដានី: ចឹងបន្ទាប់ពីឌុចមកមានដឹងថាកាត់ទោសពីណាទៀតមានដឹងទេ?

វណ្ណា: មានអៀង សារី ខៀវ សំផនអី មាននួន ជាអីហ្នឹង ។

ដានី: អរ ។

វណ្ណា: ហើយប្រពន្ធអៀង សារី អៀង ធិរិទ្ធ ។

ដានី: បាទ! ចឹងក្រោយទៀតមានឮតុលាការអីមានស៊ើបអង្កេតករណី០០៣អីទៀតមានដែលឮពត៌មានហ្នឹងទេ?

វណ្ណា: អត់ដែលបាន អត់ដែលបើកប៉ះទេ ។

ដានី: ចឹងមិនដែលដឹងទេ?

វណ្ណា: បាទ ។

ដានី: ចឹងចំពោះយោបល់ពូផ្ទាល់ពូយល់ឃើញយ៉ាងម៉េចដែរ ថាតុលាការអីគេប្រុងស៊ើបអង្កេតចោទប្រកាន់ករណី០០៣បន្តទៀតហ្នឹង ចំពោះពូផ្ទាល់ពូយល់ឃើញយ៉ាងម៉េចដែរ?

វណ្ណា: ចំពោះខ្ញុំតុលាការចោទប្រកាន់ពិតជាត្រឹមត្រូវរបស់គេហើយ ព្រោះគេមើលឃើញការសម្លាប់មនុស្សហ្នឹងវាអយុត្តិធម៌ពេក ។

ដានី: បាទ!ប៉ុន្តែយើងមានកាត់ឌុចហើយកាត់០០២ហើយជាមួយអៀង សារី អៀង ធិរិទ្ធ នួន ជា ខៀវ សំផន?

វណ្ណៈ: បាទ ។

ដានី: ហើយគេបន្តចោទប្រកាន់ចាប់មេដឹកនាំផ្សេងៗទៀត?

វណ្ណៈ: បាទ ។

ដានី: ករណី០០៣ចាប់មនុស្សបន្តផ្សេងៗទៀតពូយល់ឃើញយ៉ាងម៉េចដែរ ពូយល់ឃើញថាវាត្រឹមត្រូវឬមួយមិនត្រឹមត្រូវ គួរតែចោទប្រកាន់បន្ថែមទៀតឬមួយក៏ចប់ត្រឹមអៀង សារី អៀង ធិរិទ្ធ ខៀវ សំផន នួន ជាហ្នឹង?

វណ្ណៈ: តាមយោបល់ខ្ញុំត្រូវបញ្ចប់ត្រឹមហ្នឹងព្រោះវាសំខាន់ថ្នាក់ដឹកនាំនោះ ថាចប់ថ្នាក់ដឹកនាំអស់វាអស់ហើយ អ្នកតូចតាចគេចេះតែបញ្ជាទៅគេត្រូវតែធ្វើតាមហើយ“អ្នកជិតខាងនិយាយថាគេឲ្យធ្វើអីយើងចេះតែធ្វើហ្នឹងហើយបងកុំពិបាកពេក បើសិនជាខុសឧទាហរណ៍ដូចជាឌុចហ្នឹងមានអ្នកអាចសាហាវជាងឌុចទៀត ក៏ថាបានដែរ ។

ដានី: ចឹងខ្ញុំអរគុណច្រើនពូដែលបានផ្តល់ពត៌មានឲ្យខ្ញុំទាក់ទងពីរឿងគុកនៅវត្តឥន្ទញ្ញាណនេះ ។

វណ្ណៈ: បាទ ។

ដានី: ចឹងខ្ញុំអរគុណច្រើនពូ ។

វណ្ណៈ: បាទ ។

**ចប់**